# សៀវភៅផែនទីមហាសមុទ្រ

ហេតុការណ៍ និង តារាងរូបរាង ស្តីពីទំនាក់ទំនងរបស់យើង ទៅនឹងមហាសមុទ្រ ឆ្នាំ ២០១៧



HEINRICH BÖLL STIFTUNG SCHLESWIG-HOLSTEIN

HEINRICH BÖLL STIFTUNG CAMBODIA

future ocean
KIEL MARINE SCIENCES

# បុព្វកថា

មហាសមុទ្រ គ្របដណ្តប់ជាងពីរភាគបីនៃផ្ទៃដីរបស់ភពផែនដីយើង ហើយមានទំហំវិមាត្រលាតសន្ធឹងធំល្វឹងល្វើយ ដាច់កន្ទុយភ្នែក ដែលតំបន់ខ្លះគឺមិនទាន់ត្រូវបានគេរុករកឃើញនៅឡើយនោះទេ។ វាផ្ទុកទៅដោយធនធានដ៏សម្បូណ៌បែបដែលផ្តល់ឱ្យយើងដូចជាចំនីអាហារ ថាមពល និងសារធាតុរ៉ែជាច្រើនទៀត។ យើងប្រើប្រាស់មហាសមុទ្រ ដើម្បីដឹកជញ្ជូនទំនិញពីទ្វីបទៅទ្វីបទៀត ហើយមហាសមុទ្រ ក៏មានសារសំខាន់ខ្លាំងណាស់ដែរក្នុងការរក្សាលំនឹងនៃបរិយាកាស និងអាកាសធាតុរបស់យើង។

ប្រសិនបើពុំមាន មហាសមុទ្រ និងធនធានរបស់វាទេ ភាពស្តុកស្តម្ភ និងសុខុមាល របស់ ប្រជាជនមួយផ្នែកនៅលើផែនដីនេះក៏ ប្រហែល ជាមិនអាចកើតមានបានដែរ។ ក្នុងបច្ចុប្បន្នភាពនេះ យើងបានមើលឃើញពី អនាគតនៃប្រព័ន្ធអេកូឡូស៊ីដ៏ពិសេសមួយនេះ កំពុងប្រឈមនឹងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ។ ដោយសារតែគោលការណ៍សេរីភាពលើដែនសមុទ្រ ដែលបានអនុវត្តរាប់រយឆ្នាំកន្លងមកនេះ បានផ្តល់សម្បទាន និងសិទ្ធិងាយស្រួលដល់មនុស្សក្នុងការប្រើប្រាស់ និងផ្សាភ្ជាប់ជីវិតទៅនឹងមហាសមុទ្រ និងធនធានរបស់វាដោយគ្មានដែនកំណត់ ដែលបានបង្កឲ្យមាន ការនេសាទហួសកម្រិត ការបាត់បង់ជីវចម្រុះ និងការបំពុលបរិស្ថានក្នុងដែនមហាសមុទ្រ។

មហាសមុទ្រ និងឆ្នេរសមុទ្រ គឺជាផ្នែកដ៏សំខាន់នៃបរិស្ថាន ហើយពួកវាត្រូវការ ការពារ និងថែរក្សាពីយើងទាំងអស់គ្នាជាបន្ទាន់ នៅក្នុង ថ្នាក់អន្តរជាតិ កំណត់ទិសដៅយ៉ាងច្បាស់លាស់ កំពុងតែមានសន្ទុះយ៉ាងខ្លាំងនៅលើឆាកអន្តរជាតិ នៅក្នុងកិច្ចព្រមព្រៀងការពារអន្តរជាតិ និងសន្និសញ្ញា ដែល កំណត់គោលដៅ និងចែករំលែកសម្រាប់បច្ចុប្បន្នភាពនិងមនុស្សជំនាន់ក្រោយ ដើម្បីរស់ឲ្យមានតុល្យភាព ជាមួយធម្មជាតិ និងដើម្បីធានាបាននូវសុខភាព និងសុចរិតភាពនៃប្រព័ន្ធអេកូឡូស៊ីជាសកល និងការស្តារឡើងវិញ។

នៅក្នុងឯកសារនៃសន្និសីទ Rio + 20 ឆ្នាំ ២០១២ រដ្ឋដែលជាសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិ បានទាមទារឲ្យមាន វិធីសាស្ត្ររួមបញ្ចូលគ្នាដែលមានភាពទូលំទូលាយ ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងវិធីសាស្ត្រប្រកបដោយចីរភាពទៅលើមហាសមុទ្រ ។ ការស្រាវជ្រាវត្រូវបានគេធ្វើ ឲ្យមានភាពល្អប្រសើរឡើងក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ ដែលអាចធ្វើ ឲ្យយើង យល់កាន់តែច្បាស់ពីប្រព័ន្ធនៃមហាសមុទ្រ និងដើម្បីបង្កើតដំណោះស្រាយសម្រាប់ ដោះស្រាយជាមួយមហាសមុទ្រ ប្រកបដោយចីរភាព។ របៀបវារៈនាឆ្នាំ ២០៣០ ដែលត្រូវបានផ្តល់សច្ចាប័នដោយអង្គការសហប្រជាជាតិ នៅក្នុងឆ្នាំ ២០១៥ ក៏បានគិតពិចារណាផងដែរអំពីសារៈសំខាន់នៃមហាសមុទ្រសំរាប់ការអភិវឌ្ឍឲ្យមាននិរន្តរភាព។ គោលដៅទាំង១៧នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព (SDGs), នៅក្នុងចំណុចទី ១៤ គឺនិយាយអំពីការការពារ និងថែរក្សាដល់មហាសមុទ្រ។ ដើម្បីឈានទៅដល់គោលដៅមួយនេះ គឺតម្រូវឲ្យមាន ការខិតខំប្រឹងប្រែងឆ្ពោះទៅរកកិច្ចសហប្រតិបត្តិការពីស្ថាប័ន

ពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្តផែនការថ្នាក់ជាតិ ថ្នាក់តំបន់ និងទូទាំងសកល។

វិធានការទាំងនេះ នឹងអាចសម្រេចជោគជ័យក្នុងរយៈពេលវែងលុះត្រាតែមានការការគាំទ្រច្រើនពីសង្គម រួមបញ្ចូលទាំង អ្នកជំនាញវិទ្យាសាស្ត្រ អ្នកវិទ្យាសាស្ត្រនយោបាយ អ្នកសេដ្ឋកិច្ច ដែលពួកគេគឺជាតួអង្គដ៏សំខាន់ មកពីសង្គមស៊ីវិល ឬជាឯកជនភាព។

នេះហើយ គឺជាតួនាទីរបស់សៀវភៅ អាត្លាស(Atlas) ដែលអ្នកកំពុងចាប់កាន់។ សៀវភៅនេះមានគោលបំណងបង្ហាញពីតួនាទីដ៏សំខាន់របស់មហាសមុទ្រ និងប្រព័ន្ធអេកូឡូស៊ី ដែលវាមិនត្រឹមតែមានសារសំខាន់សម្រាប់មនុស្សរស់នៅលើឆ្នេរប៉ុណ្ណោះទេ ប៉ុន្តែវា ក៏សម្រាប់យើងទាំងអស់គ្នាផងដែរ។ តើមានធនធានសម្បត្តិ និងសុខុមាលភាពអ្វីខ្លះ ដែលមហាសមុទ្រផ្តល់ឲ្យពួកយើង? តើយើងគួរគ្រប់គ្រងធនធានរបស់វាយ៉ាងដូចម្តេច?តើស្ថានភាពសុខភាពរបស់ប្រព័ន្ធអេកូឡូស៊ីសមុទ្រគឺជាអ្វី? ហើយ តើអ្វីទៅជាការគំរាមកំហែងសំខាន់ៗ ដែលវាកំពុងតែប្រឈមមុខ? តើបម្រែបម្រួលអាកាសធាតុដែលបង្កឡើងដោយមនុស្ស ប៉ះពាល់ដល់មហាសមុទ្រ និងឆ្នេរយ៉ាងដូចម្តេច? តើអ្វីទៅជាការតភ្ជាប់ រវាងការប្រើប្រាស់ប្រកបដោយនិរន្តភាពនៃធនធានសមុទ្រ និងការផ្លាស់ប្តូរនៅក្នុងការផលិត និងគម្រូនៃការប្រើប្រាស់របស់យើង?

យើងសង្ឃឹមថា វានឹងមានការជំរុញឲ្យមាន កិច្ចពិភាក្សាសង្គម និងនយោបាយឲ្យបានទូលំទូលាយ ស្តីអំពីសារៈសំខាន់របស់មហាសមុទ្រ ដែលជាប្រព័ន្ធមួយ និងលទ្ធភាពក្នុងការការពារវា។

មេរៀនខ្លីៗទាំង ១២

# អំពីមហាសមុទ្រ និង ពិភពលោក

១ មហាសមុទ្រ គឺជាប្រភពនៃជីវិត និងជីវភាពសម្រាប់កំណើនប្រជាជនពិភពលោក។ ប្រជាជនចំនួន ២.៩ពាន់លាននាក់ នៅជុំវិញពិភពលោក ២០ភាគរយនៃតម្រូវការប្រូតេអ៊ីនរបស់ពួកគេគឺបានមកពីត្រី។ អាកាសធាតុរបស់ផែនដី គឺបានរងឥទ្ធិពលយ៉ាងខ្លាំង ពីអន្តរកម្មរវាងបរិយាកាស និងមហាសមុទ្រ។ បើសិនជា គ្មានមហាសមុទ្រទេ យើងក៏មិនអាចរស់រានមានជីវិតបានដែរ។



២ មហាសមុទ្រ គឺកំពុងតែស្ថិតនៅក្រោមភាពតានតឹងដ៏ខ្លាំងខ្លា ដោយសារកត្តាមួយចំនួន។ ស្ថានភាពនេះ មិនមែនបណ្តាលមកពីបញ្ហាតែមួយនោះទេ ប៉ុន្តែគឺមានបញ្ហាជាច្រើនបានកើតឡើងស្របគ្នា។ ពួកយើងកំពុងមានវិបត្តិមហាសមុទ្រ!

៣ មហាសមុទ្រ គ្របដណ្តប់ ៧១ភាគរយនៃសកលលោកទាំងមូល។ សមុទ្រកំពុងទទួលរងគ្រោះ ដោយសារតែការប្រែប្រួលអាកាសធាតុ។ អាសុីត កម្តៅ និងកំណើននីវ៉ូទឹកសមុទ្រ បានផ្លាស់ប្តូរបរិស្ថានជុំវិញរួចទៅហើយ។ នីវ៉ូទឹកសមុទ្រជាសកល បានកើនឡើង ២០សង់ទីម៉ែត្រ នៅក្នុងរយៈពេលរាប់រយឆ្នាំចុងក្រោយនេះ។ តាមតួលេខនោះវាអាចនឹងកើន ឡើងដល់១ម៉ែត្រនៅចុងសតវត្សនេះ។

៤ ពួកយើងកំពុងតែប្រមូលផលលើសពី អ្វីដែលមហាសមុទ្រអាចផ្តល់អោយយើង ពោលគឺយើងកំពុងតែកេងប្រវ័ញ្ចហួសកម្រិតទៅលើមហាសមុទ្រជាឧទាហរណ៍ ការនេសាទត្រីហួសប្រមាណដែល ៩០ ភាគរយនៃចំនួនត្រីនៅលើពិភពលោក ត្រូវបានធ្វើអាជីវកម្មជាអចិន្ត្រៃយ៍ ឬត្រូវបាននេសាទហួសកម្រិត។ ការថយចុះនៃជីវចម្រុះនេះ គឺជាបញ្ហាចម្បងដែលយើងកំពុងជួបប្រទះ។





៥ យើងប្រើប្រាស់មហាសមុទ្រ ជាកន្លែងផ្ទុកកាកសំណល់។ មហាសមុទ្រផ្ទុកច្រើនជាងសមត្ថភាពដែលវាអាចទទួលបាន ដូចជា ឧស្ម័នផ្ទះកញ្ចក់ លាមក ជី ប្លាស្ទិច ការបំពុលប្រេង និងមានជាច្រើនទៀត។ ជាលទ្ធផល៖ នេះគឺជាការបំផ្លាញប្រព័ន្ធអេកូឡូស៊ីរបស់មហាសមុទ្រ។

៦ ទំនាក់ទំនងរបស់យើងទៅនឹងមហាសមុទ្រ គឺពេលខ្លះមិនអាចមើលឃើញទេ។ អ្វីដែលយើងញាំ អ្វីដែលយើងប្រើប្រាស់សម្រាប់សម្អាត កន្លែងដែលយើងធ្វើដំណើរ សម្លៀកបំពាក់ដែលយើងស្លៀកពាក់ អ្វីៗទាំងអស់នេះ គឺជះឥទ្ធិពលទៅលើមហាសមុទ្រ។



៧ ប៉ុន្តែនេះគ្រាន់តែជាការចាប់ផ្តើមនៃ **ឧស្សាហូបនីយកម្មនៃមហាសមុទ្រ តែប៉ុណ្ណោះ។** ការផ្លាស់ប្តូរសំខាន់ៗ គឺនៅវែងឆ្ងាយទៅមុខទៀត។ តម្រូវការលើធនធានធម្មជាតិ និងថាមពលពីបាតសមុទ្រ មានវិសាលភាពធំធេង និងកាន់តែដុះ លូតលាស់នាពេលអនាគត។



៨ **ភាពអាថ៌កំបាំងជាច្រើនទៀតនៃបាតសមុទ្រ** មិនទាន់បានរុករកឃើញអស់នៅឡើយទេ។ ការជីករករ៉ែនៅបាតសមុទ្រ អាចបំផ្លាញប្រព័ន្ធអេកូឡូស៊ីទាំងស្រុង មុនពេលដែលយើងអាចនឹងដឹងថាវាមានពិតមែន។



៩ **នៅទីនោះអាចមានធនធានគ្រប់គ្រាន់សម្រាប់អ្នកទាំងអស់គ្នា។** វិធីសាស្ត្រដែលត្រឹមត្រូវ និងមាននិរន្តរភាព ដើម្បីដោះស្រាយជាមួយធនធានធម្មជាតិ គឺអាចទៅរួច។ បុរេលក្ខណៈដែលចាំបាច់នោះគឺ ការប្រើប្រាស់ដោយយកចិត្តទុកដាក់ ការបែងចែកដែលមិនលំអៀង និងការគ្រប់គ្រងជលផលដ៏ប៉ិនប្រសប់។



១០ បើសិនជា យើងនៅតែបន្តធ្វើអ្វីដែលយើងកំពុងធ្វើឥឡូវនេះ មនុស្សជាច្រើននឹងបាត់បង់ ជីវភាពរស់នៅរបស់ពួកគេ។ **អ្នកដែលក្រីក្របំផុត គឺជាអ្នកដែលរងផលប៉ះពាល់ខ្លាំងជាងគេ។** ការចំណាកស្រុក និងក្លាយទៅជាការសម្រេចចិត្តចុងក្រោយ។



១១ មហាសមុទ្រព័ទ្ធជុំវិញពិភពលោក។ ប៉ុន្តែ **ពុំមានអាជ្ញាធរអន្តរជាតិកំពូលពិតប្រាកដណាមួយ ដែលទទួលខុសត្រូវ** ចំពោះការការពារមហាសមុទ្រទាំងមូលនោះទេ។ ជាលទ្ធផលគឺវាធ្វើឲ្យដែនសមត្ថកិច្ចទាំងអស់ត្រូវបានបែងចែកជាចំណែកតូចៗ ច្បាប់គ្រប់គ្រាន់និងមានចន្លោះប្រហោងជាច្រើនទៀត។

១២ ប៉ុន្តែ ទោះជាយ៉ាងណាវានៅតែមានការផ្លាស់ប្តូរទៅរកទិសដៅដែលត្រឹមត្រូវ។ វិបត្តិមហាសមុទ្រ កំពុងតែក្លាយទៅជាចំណុចផ្តោតអារម្មណ៍។ មនុស្សជុំវិញពិភពលោក កំពុងតែចាប់ផ្តើមផ្លាស់ប្តូរឥរិយាបថ និងការប្រើប្រាស់របស់ពួកគេ។ នៅក្នុងសន្និសីទស្តីអំពីមហាសមុទ្ររបស់អង្គការសហប្រជាជាតិ ២០១៧ ដែលបានធ្វើឡើងនៅទីក្រុងញូវ យ៉ក **សហគមន៍នៃពិភពលោកទាំងអស់ គឺកំពុងចាប់ផ្តើមធ្វើការជាមួយគ្នាក្នុងការការពារមហាសមុទ្រ។**

CC-BY-SA PETRABOECKMANN.DE / OCEAN ATLAS 2017

# ត្រីស្ទើរតែអស់ពីស្តុក?

ត្រី គឺជាស្នូលនៃសន្តិសុខស្បៀងអាហារសកល។ វាគឺជាផលិតផលធម្មជាតិ ដែលត្រូវបានជួញដូរច្រើនជាងគេបំផុតលើពិភពលោក។ ប៉ុន្តែការពឹងផ្អែកជាសកលលើត្រី គឺពិតជាមានការគំរាមកំហែងធំបំផុតចំពោះត្រីរបស់យើង។ ពួកវាច្រើន ត្រូវបានគេនេសាទហួសប្រមាណ ហើយករណីនេះកំពុងតែកើនឡើងជាលំដាប់។

រាប់ពាន់ឆ្នាំមកហើយ បុព្វបុរសរបស់យើងគឺពឹងផ្អែកនៅលើរបរនេសាទ ដើម្បីចិញ្ចឹមជីវិតរបស់ពួកគាត់។ នៅលើដីគោក ការប្រមាញ់ និងការប្រមូលផលសម្រាប់ចិញ្ចឹម ជីវិតត្រូវបានជំនួសដោយ របរកសិកម្មដាំដុះនៅនឹងកន្លែង។ ចំណែកអ្នកនៅតំបន់សមុទ្រ ការនេសាទត្រីគឺជាវត្ថុបំណងតែមួយគត់ដែលគ្រប់គ្នាធ្វើការប្រមាញ់យកផល។ អ្នកដែលធ្វើការនេសាទទាំងអស់នោះមិនបាន សាបព្រោះដាំដុះទេ គឺមានតែការប្រមូលផលប៉ុណ្ណោះ។

ឥរិយាបថនៃការបរបាញ់នេះ រួមជាមួយនឹងការកើតឡើងនៃតម្រូវការត្រីសម្រាប់ចិញ្ចឹមជីវិត គឺបណ្តាលមកពីកំណើនប្រជាជនលើសកលលោកដែលកំពុងកើនឡើងខ្លាំងបានធ្វើឲ្យ ចំនួនត្រីលើពិភពលោកមានការថយចុះ។ យោងទៅតាម អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិបានឲ្យដឹងថា ប្រហែល ៣០ភាគរយនៃត្រី ត្រូវបាននេសាទហួសកម្រិត ឬត្រូវបាត់បង់ ដោយសារពួកវា មិនត្រូវបានគេទាញយកផលប្រយោជន៍ប្រកបដោយនិរន្តរភាព។ ចំណែក ៥៨ភាគរយ ផ្សេងទៀត ត្រូវបានគេគិតគូជម្រុញឲ្យមាននិរន្តរភាព។ នោះមានន័យថា ប្រមាណជា ៩០ភាគរយនៃចំនួនត្រីសរុបដែលត្រូវបានគេធ្វើអាជីវកម្មទូទាំងពិភពលោកគឺមានការថយចុះ។ ការកេងប្រវ័ញ្ចបែបនេះគឺមិនអាចកើតមានទៀតទេនៅថ្ងៃខាងមុខ។ យើងក៏មិនត្រូវ បាត់បង់ក្តីសង្ឃឹមទាំងអស់នោះដែរ។ ត្រីភាគច្រើនអាចកើតឡើងវិញបាន នៅគ្រប់ទីកន្លែងចាប់ពី ៣ ឬ ៤ ឆ្នាំទៅ២ ឬ ៣ ទសវត្សរ៍ទៅមុខទៀតជាមួយនឹងវិធីសាស្ត្រនៃការគ្រប់គ្រងនេសាទប្រកបដោយភាពឆ្លាតវៃ។ ភាពជោគជ័យជាឧទាហរណ៍ជាច្រើនដូចជានៅ សហរដ្ឋអាមេរិច ប្រទេសញូវ ហ្សេលែន ប្រទេសអូស្ត្រាលី ប្រទេសន័រវេ Norway និងប្រទេសជាសមាជិកសហភាពអឺរ៉ុបដទៃទៀត។ ចំនួនត្រីជាច្រើន បានកកើតឡើងវិញនៅទីនោះ។ នៅឆ្នាំ ២០០៩ សមុទ្រជាច្រើននៅអឺរ៉ុប មានការនេសាទហួសកម្រិតដល់ទៅ ៩០ភាគរយ។ តែសព្វថ្ងៃ តួរលេខនេះបានថយចុះដល់ទៅ៥០ភាគរយ ដោយសារតែមានការរឹតបន្តឹងខ្លាំង និងការដាក់កំណត់នៅលើការចាប់ត្រី។

ប៉ុន្តែមិនមែនចំនួនត្រីទាំងអស់ ស្ថិតក្នុងស្ថានភាពមួយដែលអាចកកើតឡើងវិញ យ៉ាងឆាប់រហ័សនោះទេ បើទោះបីជាពួកវាត្រូវបានធ្វើអាជីវកម្មប្រកបដោយចីរភាពក៏ដោយ។ ក្រុមមួយចំនួននៃត្រីធំៗ ដូចជា ត្រីម៉ាឡែន ត្រីដាវ ត្រីឆ្លាម និងត្រីមរ៉ុយ បានធ្លាក់ចុះយ៉ាងខ្លាំងរហូតដល់ ៩០ភាគរយ។ ផ្សោត និងអណ្តើកសមុទ្រ ដែលរងគ្រោះដោយការចាប់ ត្រូវបានគំរាមកំហែងមួយផ្នែកដោយសារការ ផុតពូជ។ ពួកវាមិនកើតឡើងវិញបានឆាប់រហ័សនោះទេ។ ប្រភេទជាច្រើននៃត្រីធូណា ជាប្រភេទពូជដែលនឹងមិនកើតឡើងវិញ ដរាបណាពួកវា នៅតែត្រូវគេនេសាទយ៉ាងសកម្មក្នុងកម្រិតណាមួយ។ តម្លៃទីផ្សាររបស់ពួកវា គឺខ្ពស់ ដែលការប្រមាញ់ពួកវានៅតែអាចរកប្រាក់ចំណូលបានច្រើន ទោះបីជាកាចាប់ក្នុងទំហំតូច ឬបានតិចក៏ដោយ។ ត្រីធូណាក្រហមមានតម្លៃខ្ពស់ណាស់ ដែលធ្វើឲ្យមានការប្រកួតប្រជែងខ្លាំងនៅលើទីផ្សារជប៉ុន។ ក្នុងឆ្នាំ ២០១៣ ចង្វាក់ផលិតកម្មបង្កើតអាហារស៊ូស៊ី បានទិញគំរូដ៏គួរឱ្យចាប់អារម្មណ៍មួយ តំលៃ ១.៣ លានអឺរ៉ូ ។ ជារួម ៨៥ភាគរយនៃការចាប់ត្រីធូណាមកពីសមុទ្រមេឌីទែរ៉ាណេ និងពីរភាគបីនៃការចាប់ជាសកលទាំងមូលគឺហូរចូលទៅប្រទេសជប៉ុន។

ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ពឹងផ្អែកជាពិសេសទៅលើការនេសាទ។ ការនេសាទ គឺជាសកម្មភាពសេដ្ឋកិច្ចចម្បងនៅ ទីនោះ។

Subventions and Catches—What's Left Over




Fisheries are heavily subsidized in all European countries. The relationship between the subsidies and the results is unequal. While Italy and Spain still turn profits, Germany actually takes a loss.

## Who Catches the Fish—and Who Eats Them?




គេបានប៉ាន់ប្រមាណថា មានអ្នកប្រកបរបរនេសាទខ្នាតតូច ប្រមាណចំនួន ១២លានអ្នក ទូទាំងពិភពលោក។ ម្យ៉ាងវិញ ទៀត ឧស្សាហកម្ម នេសាទ ប្រើប្រាស់មនុស្សចំនួនតែ ៥០០០០០ នាក់ប៉ុណ្ណោះ។ មនុស្សម្នាក់ដែលធ្វើការក្នុងឧស្សាហកម្មទាំងនេះធ្វើការនេសាទជាច្រើនដង ខុសពីអ្នកនេសាទជាលក្ខណៈសិប្បកម្មតូចៗ ដោយគ្រាន់តែប្រមូលផលពីសមុទ្រជាមួយសំណាញ់របស់ពួកគេ។ កប៉ាល់រោងចក្រជាច្រើនដែល មានផ្ទុកឧបករណ៍ទំនើបៗដូចជា ឧបករណ៍រលកសំលេង យន្តហោះយកការណ៍ និងសំណាញ់ធំៗ ពួកគេកំពុងតែបំផ្លាញការចាប់ត្រីតាមបែបប្រពៃណី។ កប៉ាល់ធំៗ ដែលធ្វើប្រតិបត្តិការជុំវិញពិភពលោកនឹងស្វែងរកកន្លែងដែលអាចចាប់ត្រីបានច្រើន ដូចជាតំបន់នៅជិតឆកសមុទ្ររបស់ទ្វីបអាព្រិចខាងលិច ដែលនៅទីនោះមានច្បាប់រដ្ឋតិចតួច ហើយពួកគេអាចផ្តួលការនេសាទក្នុងស្រុកបានយ៉ាងស្រួល។

បញ្ហាធំមួយទៀតសម្រាប់ការថែរក្សាចំនួនត្រី គឺការ នេសាទត្រីខុសច្បាប់ គ្មានការគ្រប់គ្រងច្បាស់លាស់ ហើយ គ្មានឯកសារគ្រប់គ្រាន់។ វាសំដៅទៅលើការចាប់ត្រី ជាមួយឧបករណ៍មិនស្របច្បាប់ ដែលគ្មានការអនុញ្ញាតត្រឹមត្រូវ វេលាមិនសមស្រប ឬនៅក្នុងតំបន់អភិរក្ស ដូចជា ការចាប់ពូជត្រី ដែលត្រូវបានគេហាមឃាត់ ឬការនេសាទច្រើនជាងអ្វីដែលគេបាន កំណត់។ ការចាប់ត្រីខុសច្បាប់ មានចំនួនដល់ទៅ ៣១ភាគរយ នៃ ការចាប់ត្រីជាសកល។ ម្ចាស់កប៉ាល់ខ្លះគេចខ្លួនពីការត្រួតពិនិត្យ របស់ប្រទេស ដោយការធ្វើនាវាចរណ៍ក្រោមទង់ជាតិជាលក្ខណៈទេសចរណ៍កំសាន្តសមុទ្រ។ អ្នកខ្លះទាញយកផលចំណេញលើស្ថានភាពជាក់ស្តែង ដែលវាមានការពិបាកក្នុងការតាមដានកប៉ាល់ខុសច្បាប់ នៅកន្លែងដូចជានៅតាមបណ្តា កោះ និងប្រជុំកោះនានានៅប្រទេសឥណ្ឌូនេស៊ី។ ករណីបែបនេះក៏កើតឡើងនៅតំបន់សមុទ្ររបស់ប៊ីរីង (Bering Sea) ដែរ គឺជាកន្លែងដែលការនេសាទខុសច្បាប់ត្រូវដែលបង្កឡើង ដោយក្រុមហ៊ុនរុស្ស៊ី និងចិន។ អាត្រានៃការនេសាទខុសច្បាប់នៅទីនោះមានចំនួន ៣៣ភាគរយ។ តាមការប៉ាន់ស្មាន ចំនួន ៥០០០០០ តោននៃការចាប់ត្រីខុសច្បាប់កើតមានឡើងរៀងរាល់ឆ្នាំ។ សហភាពអឺរ៉ុបបានធ្វើការណែនាំដល់ក្រុម ត្រួតពិនិត្យកំពង់ផែយ៉ាងតឹងរឹង ប៉ុន្តែការចាប់ត្រីខុសច្បាស់ទាំងនោះ នៅតែត្រូវបានរកឃើញនៅខាងសហគមន៍អឺរ៉ុប។

ប្រសិទ្ធិភាពនៃផ្នែកនយោបាយ ក៏រួមចំណែកនៅក្នុងការដាក់សំពាធលើចំនួនត្រីផងដែរ។ ឧទាហរណ៍ជាច្រើនឆ្នាំកន្លងមកនេះនៅ ក្នុងប្រទេសអេស្ប៉ាញ និង ប័រទុយហ្គាល់ ការភ័យខ្លាចក្នុងការអត់ ការងារធ្វើ ការឧបត្ថម្ភជាវិភាគទានដល់កងនាវា ដែលជាហេតុធ្វើឲ្យ វិស័យជលផលរបស់ពួកគេមានការចុះខ្សោយ។

ប្រសិនបើក្រសួងជលផលអនុវត្តជាប្រព័ន្ធតាមអនុសាសន៍វិទ្យាសាស្ត្រ ដែលក្នុងរយៈពេលវែងមួយ ពួកគេយកតែទិន្នផលដែលមាននិរន្តរភាពអតិបរិមា នោះការនេសាទនៅលើពិភពលោក ពិតជានឹងក្លាយជាធនធានដែលចេះតែកើនឡើង ដែលយើងសន្មត់ថាវាខុសនោះ។ ការបញ្ចប់ការឧបត្ថម្ភធនដូចជាការឧបត្ថម្ភធនឥន្ធនៈ នឹងក្លាយជាការចាប់ផ្តើមដ៏ល្អមួយ។ ●

## Fewer Fish Than Ever Before




58% of global marine fish stocks are fully fished and 31% are overfished; only 10% are not at or over their limits.

ការបំពុល

# កាកសំណល់នៅលើផ្ទៃទឹក ជាថ្នាំពុលបំផ្លាញនៅក្នុងសមុទ្រ

គំនរនៃថង់សំរាមជាច្រើន នៅលើផ្ទៃរបង្កបញ្ហាយ៉ាងជាក់ស្តែង។ ប្រភេទផ្សេងៗទៀតនៃការបំពុល មិនសូវមើលឃើញ ប៉ុន្តែការបំពុល តែបន្តិចបន្តួចក៏នៅតែជាបញ្ហាដែរ។



## សារជាតិនីត្រាត និង សារជាតិហ្វូស្វាត

**បុព្វហេតុ៖** ចេញមកពីកសិកម្មឧស្សាហកម្មដូចជា ការចញ្ចឹមសត្វ និងការដាំដុះតាមបែបប្រពលវប្បកម្ម។

**ឥទ្ធិពល និងនិន្នាការ៖** ចាប់តាំងពីឆ្នាំ ១៩៥០ និង ១៩៦០ មក វិស័យកសិកម្មនៅជុំវិញពិភពលោក បានអភិវឌ្ឍខ្លួនទៅជាឧស្សាហកម្មខ្នាតធំ។ សារធាតុដែលចេញពីជីលាមកសត្វ សត្វ និងជីសិប្បកម្មបានហូរចូលទៅក្នុងទន្លេ តាមរយៈទឹកក្រោមដី ហើយបញ្ចប់នៅឯសមុទ្រ ជាលទ្ធផលបង្កឲ្យក្លាយជាតំបន់គ្រោះថ្នាក់ដល់ជីវិតនៅឯផ្ទៃរសមុទ្រ។ កិច្ចព្រមព្រៀងអន្តរជាតិ ព្យាយាមលុបបំបាត់ផលប៉ះពាល់ទាំងអស់នោះ តាមការកាត់បន្ថយការបង្ហូរកាកសំណល់។





## កាកសំណល់ផ្លាស្ទិក

**បុព្វហេតុ៖** មានកាកសំណល់ផ្លាស្ទិកចំនួន ២០ភាគរយ តែប៉ុណ្ណោះ ដែលហូរចូលសមុទ្រ គឺដោយសារសមុទ្រខ្លួនវា។ ចំណែក ៨០ភាគរយ ទៀតគឺបានមកពីតំបន់ដីស្ងួត ដែលភាគច្រើនចេញមក ពីប្រទេសដែល គ្មានការគ្រប់គ្រងសំរាម ឬខ្សោយនៅក្នុងការគ្រប់គ្រង។

**ឥទ្ធិពល និង និន្នាការ៖** មានកន្លែងផ្ទុកសំរាមធំៗចំនួន៥ ដែលត្រូវបានគេស្គាល់។ សំរាមភាគច្រើន ស្ថិតនៅតាមបណ្តោយផ្ទៃរជុំវិញពិភពលោក ហើយបង្ក បញ្ហាដល់ពិភពលោកទាំងមូល។ ឧទាហរណ៍ នៅក្នុងឆ្នាំ ២០១៥ គេបានរើសកាកសំណល់ ចំនួន១០០ម៉ែត្រគូបនៅលើ ផ្ទៃររបស់កោះ Spitsbergen ដែលវា ជាកោះដាច់ស្រយាលមួយ ពាក់កណ្តាលផ្លូវរវាង ប្រទេស ណ័រវេ (Norway) និងប៉ូលខាងជើង។ គំនរពំនូកសំរាម កើនធំឡើងៗជារៀងរាល់ឆ្នាំ។

## សារជាតិគីមី និង លោហៈរឹង

**បុព្វហេតុ៖** បានមកពីសំណល់រាវរបស់ ឧស្សាហកម្ម និងកាកសំណល់ឧស្មន័តាមរយៈការជីកយករ៉ែ និងការដុតកំម្តៅប្រេង។

**ឥទ្ធិពល និង និន្នាការ៖** យោងតាម អូអ៊ីស៊ីឌី (the OECD) មានសារជាតិគីមីប្រហែលជា ១០០,០០០ប្រភេទផ្សេងគ្នា ធ្វើចលនាសាយភាយជុំវិញពិភពលោក។ ពួកវាមានរួមបញ្ចូលទាំងលោហៈរឹង ដូចជាសំណរ និងបារតហើយក្រៅពីនេះ គឺនៅមានសារធាតុបំពុលសរីរាង្គដែលមិនរលាយមួយចំនួនទៀត (POP)។ សារធាតុជាច្រើនគឺមានឥទ្ធិពលបង្កឲ្យមានបញ្ហាខ្លាំងណាស់ ព្រោះពួកវាប្រមូលផ្តុំនៅក្នុងសារពាង្គកាយមាន ជីវិតដែលរស់នៅក្នុងសមុទ្រ ហើយវានឹងបញ្ជូនតទៅក្នុងចង្វាក់ផលិតកម្មអាហារ ដែលពួកវាអាចបង្កហានិភ័យដល់សុខភាពរបស់មនុស្ស។

## វិទ្យុសកម្មភាព

បុព្វហេតុ៖ បណ្តាលមកពីប្រទេសដែលមានថាមពល អាតូម និងអំណាច ក្នុងការបង្កើតរោងចក្រផលិតថាមពលអាតូម ដូចជា សហរដ្ឋអាមេរិច ប្រទេសរុស្សី ប្រទេសជប៉ុន និងបណ្តាប្រទេសជាច្រើនទៀត នៃសហភាពអឺរ៉ុប ជាដើម។

ឥទ្ធិពល និងនិន្នាការ៖ ចាប់តាំងពីឆ្នាំ ១៩៥០ ប្រទេសជាច្រើនបានចាប់ផ្តើម យកធុងដែលចេញមកពីរោងចក្រថាមពលនុយក្លេអែរ របស់ពួកគេ ទៅចាក់ចោលក្នុងមហាសមុទ្រ។ ធុងដែលផ្ទុកសារធាតុជាច្រើនដែលបានរក្សាទុកនៅក្នុង ផ្លូវទឹក ប្រទេសអង់គ្លេស អស់រយៈពេលរាប់រយឆ្នាំមកហើយនោះ បានចាប់ផ្តើមធ្លុះធ្លាយលេចចេញរួចហើយ។ ការចាក់ចោល កាកសំណល់អាតូមនៅក្នុងសមុទ្រត្រូវបានគេហាមឃាត់ដាច់ខាត នៅឆ្នាំ ១៩៩៣។ ប៉ុន្តែការហាមឃាត់នេះ សំដៅទៅលើសំណល់អាតូមរឹង តែប៉ុណ្ណោះ។ ការបញ្ចេញកាកសំណល់អាតូមរាវទៅក្នុងមហាសមុទ្រ គឺនៅតែត្រូវបានអនុញ្ញាត ឲ្យអនុវត្តដដែល។ មហន្តរាយនុយក្លេអ៊ែរនៅ ទីក្រុងហ្វូគូស៊ីម៉ា (Fukushima) ក៏ដូចជាការសាកល្បង អាវុធនុយក្លេអ៊ែរ ដែលធ្វើឡើងដោយប្រទេសមហាអំណាច បានផ្តល់ផលប៉ះពាល់ គួរឲ្យកត់សម្គាល់។



## គ្រាប់រំសេវ និងសារធាតុផ្ទុះនៅក្នុងមហាសមុទ្រ

បុព្វហេតុ៖ បណ្តាលមកពីសង្គ្រាមលោកជាច្រើនលើកច្រើនសារ និង ជម្លោះដ៏ទៃទៀត។ ប្រទេសជាច្រើន នៅជុំវិញពិភពលោក បានចាក់ចោលសារធាតុគីមី ក៏ដូចជាអាវុធសាមញ្ញផ្សេងៗទៅក្នុងមហាសមុទ្រ។

ឥទ្ធិពល និង និន្នាការ៖ តាមទស្សនយល់ឃើញរបស់អ្នកជំនាញការ ការបោសសម្អាត និងស្រង់យករំសេវ និងសារធាតុផ្ទុះ មកវិញគឺត្រូវចំណាយថវិកាច្រើនឥតគណនា ហើយមានហានិភ័យខ្ពស់ទៀតផង។ ប៉ុន្តែ បើ រក្សាទុកពួកវាក៏មានហានិភ័យខ្ពស់ដែរ។ ជាឧទាហរណ៍ ៧០ឆ្នាំ ក្រោយសង្គ្រាមលោកលើកទី២ បណ្តុំសារធាតុផូស្វ័រពណ៌ស ដែលបន្សល់ពីគ្រាប់បែក នៅតែត្រូវបានរលកបក់យកមកឆ្នេរវិញ។ ពួកវាមើលទៅមាន ពណ៌លឿងខ្ចី ហើយក្មេងៗចូលចិត្តប្រមូលវាលេងណាស់។ ផូស្វ័រផ្ទុះទៅជាអណ្តាតភ្លើង នៅពេលដែលវាប៉ះជាមួយអុកស៊ីសែន និងកម្តៅ។ នៅកម្តៅ១៣០០អង្សា វាអាចឆេះដល់ឆ្អឹង។ កាកសំណល់យោធានេះ អាចនៅតែបន្តផ្តល់ការគំរាមកំហែងរយៈពេលវែង ទៅដល់ពេលអនាគតទៀត។





## ការបំពុលប្រេង

បុព្វហេតុ៖ កើតចេញពីកាកសំណល់រាវដែលលេចធ្លាយ អំឡុងពេលខួងប្រេង ការដឹកជញ្ជូនប្រេង ការលាងធុងប្រេងខុសច្បាប់ ការកំពប់ប្រេង និងគ្រោះថ្នាក់ដោយ ចៃដន្យផ្សេងៗទៀតអំឡុងពេលខួងយកប្រេង។

ឥទ្ធិពល និង និន្នាការ៖ វាត្រូវការរយៈពេលសម្អាត ៣ ឬ ៤ខែ ឬរហូតដល់ ៥ឆ្នាំ ដើម្បីធ្វើឲ្យឆ្នេរខ្សាច់ និងថ្ម អាចត្រឡប់មកដូចសភាពដើមវិញបាន ចំណែកផ្កាថ្ម និង ជម្រកឆ្នេរថ្មត្រូវការរយៈពេលចាប់ពី ២ ឬច្រើនជាង ១០ឆ្នាំ។ ទោះបីជា ការជីកយកប្រេង មានអត្រាកើនខ្លាំងជាងធម្មតា ប៉ុន្តែការបំពុលតាមរយៈ ការលេចកំពប់ប្រេង មានការថយចុះដោយសារតែច្បាប់ ដឹកជញ្ជូនតាមផ្លូវទឹកមានភាពតឹងរឹងខ្លាំងជាងមុន។ ផ្ទុយមកវិញ ហានិភ័យនៃគ្រោះមហន្តរាយដោយសារ ការបូមយកប្រេង មានការកើនឡើងនៅពេលដែល យើងជីកកាន់តែជ្រៅទៅៗ។



## សូរសំលេង

បុព្វហេតុ៖ ចេញមកពីការដឹកជញ្ជូនតាមកប៉ាល់ ការជីក យករ៉ែនៅក្នុងបាតសមុទ្រ សកម្មភាព យោធា ការស្វែងរកប្រេងនិងឧស្ម័នបម្រុង ជាមួយ ម៉ាស៊ីនបំពងសំលេងចម្ងាយឆ្ងាយ (LRADs) និង ការទាញយកប្រេង និងឧស្មន័ធម្មជាតិជាដើម។

ឥទ្ធិពល និង និន្នាការ៖ កម្រិតសំលេងរំខាននៅក្នុង មហាសមុទ្រ គឺកំពុងតែកើនឡើង តាមរយៈការកើនឡើងនៃការបន្តប្រើប្រាស់នៅក្នុងមហាសមុទ្រ។ ត្រី និងថនិកសត្វសមុទ្រ ជាពិសេស ដូចជាត្រីបាឡែន ផ្សោតសមុទ្រ ដែលប្រើទំនាក់ទំនងគ្នា ដោយ រលកសំលេងកំពុងតែទទួលផលប៉ះពាល់។វាបង្កឲ្យមាន ភាពយល់ច្រឡំ និងចលាចលដល់សត្វទាំងអស់នោះ ឲ្យធ្វើដំណើរឡើងមកលើឆ្នេរ ហើយស្លាប់ដោយសារ ទឹករាក់។

CC-BY-SA PETRABOECKMANN.DE / OCEAN ATLAS 2017

## ការឡើងកម្តៅ

# កម្តៅទឹកសមុទ្រ និង ការកើនឡើងនៃហានិភ័យ

មហាសមុទ្រ គឺនៅឆ្ងាយ ឆ្ងាយពីទីក្រុង ស្រ្តីងដែល (Springdale) នៃប្រទេស អារកាន់សាស (Arkansas) ដែលស្ថិតនៅជើងភ្នំ អូហ្សាក់ ( Ozark)។ ប៉ុន្តែទីក្រុងនេះ កំពុងតែទទួលឥទ្ធិពលពីកំណើននីវ៉ូទឹកសមុទ្រ។ ក្នុងការស្វែងរកកន្លែងមានសុវត្ថិភាព ប្រជាជន ១០០០០នាក់ ក្នុងចំណោម ៧២០០០នាក់ នៅលើកោះ ម៉ាសសល (Marshall) បានយកទីក្រុងនេះ ធ្វើជាផ្ទះថ្មីរបស់ពួកគេ។

កោះ ម៉ាសសល(Marshall) ស្ថិតនៅក្នុង មហាសមុទ្រប៉ាស៊ីហ្វិក ចន្លោះកោះហាវ៉ៃ និងប្រទេស អូស្រ្តាលី។ រដ្ឋដែលជាដែនកោះ នេះ គឺជា ប្រទេសមួយក្នុងចំណោមប្រទេស ជាច្រើន ដែលជីវិតរបស់វា ត្រូវបានគំរាមកំហែង ដោយសារការប្រែប្រួលអាកាសធាតុ។ អ្វីដែលជាបញ្ហាគឺពេលវេលាតែ ប៉ុណ្ណោះ មុនពេលដែលវាត្រូវបាន រងគ្រោះខ្លាំង ហើយមាន ២/៣នៃចំនួនប្រជាជនសរុប បានចាកចេញស្វែងរកទីមានសុវត្ថិភាពនៅសហរដ្ឋអាមេរិច។

មូលហេតុនៃការចាកចេញរបស់ពួកគេ គឺដោយសារតែកំណើនយ៉ាងឆាប់រហ័សរបស់នីវ៉ូទឹកសមុទ្រ។ កត្តាមួយដែលជម្រុញកំណើននេះ គឺការរលាយផ្ទាំងទឹកកកនៅលើទ្វីប។ កត្តាមួយផ្សេងទៀត គឺការកើនឡើងកម្តៅរបស់មហាសមុទ្រ៖ ៩៣ភាគរយនៃកម្តៅបន្ថែមបានពីកម្តៅភពផែនដីដែល ត្រូវបានស្រូបយកដោយមហាសមុទ្រ។ ដោយសារតែទឹករីកមាឌ នៅពេលដែលវាក្តៅ ដូចនេះនីវ៉ូទឹក សមុទ្រក៏កើនឡើងផងដែរ។ ការរលាយរបស់ទឹកកក និងកម្តៅភពផែនដី កំពុងចូលរួមចំណែកស្មើតែស្មើគ្នា ដែល បណ្តាលឲ្យមានកំណើននីវ៉ូទឹកសមុទ្រ។ ចាប់តាំងពីឆ្នាំ ១៩០០ នីវ៉ូទឹកសមុទ្របានកើនឡើងចំនួន ២០សង់ទីម៉ែត្រជាមធ្យម។ វាត្រូវបាន គេសន្និដ្ឋានទុកថានឹងបន្តកើនឡើងក្នុងកម្រិត ៣ សង់ទីម៉ែត្របន្ថែម ទៀតជារៀងរាល់ឆ្នាំ។ កម្រិតនៃការកើនឡើងនេះហាក់បីដូចជាមិនច្រើនទេ ប៉ុន្តែសម្រាប់រដ្ឋ ដែលជាកោះរាបស្មើ មិនស្ថិតនៅជាប់គ្នាដូចជាកោះ ម៉ាសសល (Marshall ) វានឹងជាគ្រោះមហន្តរាយធ្ងន់ធ្ងរណាស់។ កាលពីមុន កោះផ្កាថ្មជាច្រើនដែលជាញឹកញាប់កើនឡើង តែ១ម៉ែត្រប៉ុណ្ណោះ ពីលើទឹករលកសមុទ្រ ហើយត្រូវជន់លិចដោយមហាសមុទ្រត្រឹមតែ ២ដងរៀងរាល់ទសវត្សរ៍។ និន្នាការនោះត្រូវបានផ្លាស់ប្តូរ គ្រាន់តែនៅក្នុងឆ្នាំ ២០១៤ កោះត្រូវបាន ទឹកលិចយ៉ាងធ្ងន់ធ្ងរចំនួន ៣ដង។ ការមានទឹកជំនន់ញឹកញាប់ពេក វាបណ្តាល់ឲ្យមាន ផលលំបាកសម្រាប់ការស្តារកោះទាំងអស់នោះ ឲ្យមានភាពល្អប្រសើរឡើងវិញ។ ដីនៅលើកោះមានសភាពប្រៃខ្លាំង ចំណែកទឹកសាបដែលរក្សាទុកនៅក្នុង អាងស្តុបទឹកក្បែរមាត់សមុទ្រ គឺមិនអាចបរិភោគបាន ហើយកោះទាំងអស់នោះ មិនអាចផ្តល់ជម្រក ដល់មនុស្សបានទៀតទេ។

កម្រិតនីវ៉ូទឹកសមុទ្រមិនកើនឡើងដូចគ្នា នៅគ្រប់ទីកន្លែងនោះទេ ហើយរង្វាស់រយៈពេលវែង បង្ហាញពីការផ្លាស់ប្តូរសំខាន់ៗ របស់តំបន់ទៅលើ សីតុណ្ហភាពផ្ទៃខាងលើរបស់មហាសមុទ្រ។ តំបន់ខ្លះ ដែលស្ថិតនៅតាមបណ្តោយចរន្តខ្សែទឹកក្តៅ ដែលហូរពីឈូង សមុទ្រម៉ិចស៊ិចកូ ស្របតាមឆ្នេរសមុទ្រសហរដ្ឋអាមេរិចធ្វើដំណើរ ឆ្លងកាត់ មហាសមុទ្រអាត្លង់ទិចឆ្ពោះទៅកាន់សហគមអឺរ៉ុបប៉ែកពាយព្យ និងរហូតទៅដល់ខ្សែទឹកមហាសមុទ្រអាត្លង់ទិចខាងជើង (Gulf Steam) បានកើនឡើងកម្តៅរហូតដល់ទៅ ៤ដងច្រើនជាង កម្តៅជាមធ្យមនៅទូទាំងសកល អំឡុងពេលដែលតំបន់ខ្លះនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិកខាងត្បូង បាន និងកំពុងតែចុះត្រជាក់បន្តិចម្តងៗ។ កោះ ម៉ាសសល (Marshall) មានទីតាំងស្ថិតក្នុងតំបន់កម្តៅ ខ្សោយ។ កម្រិតនីវ៉ូទឹកសមុទ្រដែលកើនឡើង មិនសូវចោទជាបញ្ហាខ្លាំងនោះទេ នៅត្រង់កន្លែងដែលមានកម្តៅខ្លាំង។ ហេតុអ្វី? បុព្វហេតុ ចម្បងនៃដំណើរផ្លាស់ប្តូរ ក្នុងតំបន់លើកម្រិតនីវ៉ូទឹកសមុទ្រគឺកម្លាំង ខ្យល់ ។ ឧទាហរណ៍ នៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក កម្លាំងខ្យល់បក់ខ្លាំង រុញច្រានបរិមាណទឹកពីទិសខាងកើត ទៅទិសខាងលិចបង្ក ឲ្យកម្រិតនីវ៉ូទឹកសមុទ្រនៅក្នុង មហាសមុទ្រប៉ាស៊ីហ្វិកខាងលិច កើនឡើងលើសពីអត្រាជាមធ្យមរបស់វា ខណៈពេលដែលកម្រិត នីវ៉ូទឹកសមុទ្រឆ្នេរភាគខាងលិចរបស់សហរដ្ឋអាមេរិចមានការធ្លាក់ចុះ។ ការអាស្រ័យទៅលើអាទិភាពរបស់កម្លាំង ខ្យល់នេះ ធ្វើឲ្យមានការលំបាក សម្រាប់អ្នកវិទ្យាសាស្រ្ត ក្នុងការផ្តល់ចម្លើយទាក់ទងទៅនឹងសំណួរមួយចំនួនដូចជា តើនឹងមានរឿងអ្វីកើតឡើង នៅក្នុងតំបន់របស់យើងនាពេលអនាគត? តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីធ្វើការបន្សាំទៅនឹងការប្រែប្រួល? បញ្ហាចម្បងនោះគឺ ពុំទាន់មានការព្យាករណ៍ ច្បាស់លាស់ណាមួយ ដែលអាចផ្តល់ទំនុកចិត្តបានថា តើកម្រិតនីវ៉ូទឹកសមុទ្រ តាមតំបន់នឹងផ្លាស់ប្តូរដោយរបៀប ណា? ពីព្រោះចរន្តផ្លាស់ប្តូរនៃកម្លាំងប្រព័ន្ធខ្យល់ក្នុងរយៈពេលវែង គឺពិបាកក្នុងការសន្និដ្ឋាន។

ប្រទេសអភិវឌ្ឍមួយចំនួនដូចជា ហូឡង់ កំពុងតែវិនិយោគលើ ការស្រាវជ្រាវ ទម្រង់ថ្មីដែលធ្វើឲ្យ មាននិរន្តរភាពក្នុងការការពារ តំបន់ឆ្នេរ។ ឧទាហរណ៍ ជំនួសដោយការសាងសង់ទំនប់ទឹក ពួកគេផ្តោតទៅលើការវដ្តនៃការចាក់បំពេញបន្ថែមខ្សាច់។ តង់ស៊ីតេ របស់វា អាចផ្លាស់ប្តូរបាន តាមរយៈកំណើននីវ៉ូទឹកសមុទ្រជាក់ ស្តែងក្នុងពេលអនាគត។ ដោយឡែកប្រទេសក្រីក្រផ្សេងទៀត មិនមានវិធានការការពារដូចនេះទេ ទៅលើផលវិបាក នៃការកើនឡើងកម្តៅ និងកំណើននីវ៉ូទឹកសមុទ្រនោះទេ។ ជាក់ស្តែងដូចជានៅក្នុង ប្រទេសបង់ក្លាដេស៖ វាជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើន ដែលមានដង់ស៊ីតេមនុស្សរស់នៅ ច្រើននៅលើពិភពលោកដែលមានចំនួនប្រជាជនប្រហែល ១៦០លាននាក់។ ដើម្បីបង្កើត កន្លែង សម្រាប់ទីលំនៅឲ្យស្របទៅតាមកំណើនប្រជាជន ផ្នែកមួយចំនួន ធំនៃព្រៃកោងកាងនៅក្នុង តំបន់ព្រៃដ៏ធំរបស់សាន់ដារបាន (Sundarbans) នៅក្នុងប្រទេសបង់ក្លាដេសត្រូវបានកាប់ចោល ហើយសាងសង់ជាកន្លែងរស់នៅសម្រាប់ប្រជាជន ដោយពួកគេបានសាង សង់ទំនប់ជារបាំងសម្រាប់ការពារពីទឹកសមុទ្រដែលព័ទ្ធជុំវិញ។

បង់ក្លាដេស ជាប្រទេសដែលស្ថិននៅកម្រិតនីវ៉ូទឹកសមុទ្រ ហើយកម្រិតនីវ៉ូទឹកសមុទ្រនៅទីនោះបានកើនឡើង ២ដងលើសពីកម្រិតមធ្យមនៅទូទាំងសកលលោកក្នុងរយៈពេលពីទសវត្សរ៍ចុងក្រោយមកនេះ។ ប្រជាជនជាង ១៣លាននាក់ក្នុងតំបន់ព្រៃសាន់ដារបាន (Sundarbans) គឺជាអ្នកដែលងាយរងគ្រោះជាងគេ។ នៅឆ្នាំ ២០០៩ តំបន់នេះត្រូវបានវាយប្រហារដោយ ព្យុះស៊ីក្លូនអៃឡា (Aila)។ ទំនប់ជាច្រើនត្រូវបានបំផ្លាញ ហើយមួយផ្នែកធំនៃតំបន់ទំនាប ត្រូវបានលិចលង់។ អ្វីដែលនៅសេសសល់គឺទិដ្ឋភាពដី និងទីតាំងដែលត្រូវបានបំផ្លាញហើយពោរពេញទៅដោយរសជាតិទឹកប្រៃ។ ជនភៀសខ្លួនចំនួន ១០ពាន់នាក់ បានភៀសខ្លួនចូលទៅរស់នៅក្នុងទីក្រុង។ នាពេលអនាគត នៅពេលដែលទំនប់ទឹកទាំងអស់ធ្លាយ ឬបែកបាក់ ប្រជាជនជាច្រើនលាននាក់ នឹងអាចក្លាយទៅជា ជនភៀសខ្លួនដោយសារបញ្ហាអាកាសធាតុ។ ឪកាសដែលអាចកើតឡើង គឺកំពុងតែមានសន្ទុះខ្លាំងឡើងៗ។ ឧតុនិយមវិទូនៅប្រទេស បង់ក្លាដេសកត់សម្គាល់ឃើញថា កំលាំងព្យុះ នៅក្នុងតំបន់កំពុងតែកើនឡើងខ្លាំងខ្លា ដែលប្រហែលជាផលវិបាកដោយផ្ទាល់គឺលើសពីកម្តៅជាមធ្យមរបស់ហាសមុទ្រឥណ្ឌា។

កំណើននីវ៉ូទឹកសមុទ្រ រួមជាមួយបាតុភូតអាកាសធាតុដ៏ខ្លាំងក្លា។ តើវាអាចទៅរួចទេដើម្បីថែរក្សាការពារកោះ និងទីក្រុងនៅតាមឆ្នេរទាំងអស់នោះ? សំនួរនេះនៅតែត្រូវបានពិភាក្សាយ៉ាងខ្លាំងខ្លា នៅក្នុង សហរដ្ឋអាមេរិច នៅពេលដែលទីក្រុងញូវ អរឡែន (New Orleans ) ត្រូវបានជន់លិចនៅឆ្នាំ ២០០៥។ ប្រទេសអ្នកមានមានជម្រើសនៃការការពារច្រើន ស្របពេលដែលប្រទេសក្រីក្រ កំពុងតែត្រូវបានវាយប្រហារយ៉ាងខ្លាំង។ តែបើយើងគិតដល់ ហេតុនៃស្ថានភាពបរិយាសថ្មី នឹងផ្ទុយគ្នាវិញប្រទេសឧស្សាហកម្មទាំងនោះទេ ដែលជាអ្នកទទួលខុសត្រូវខ្លាំងបំផុតទៅលើ ប្រជាជនតាមឆ្នេរសមុទ្រទូទាំងពិភពលោក។ មួយជំហានបន្តទៅទៀតគឺការប្រកៀកស្មា ដែលបន្ទុក និងការការពារតំបន់ដែលងាយរងគ្រោះ ទាំងអស់នោះ គឺការបង្កើតថវិកាអាកាសធាតុបៃតងរបស់អង្គការសហប្រជាជាតិ (the creation of UN′s Green Climate Fund) ដែលវាអាចជួយឲ្យប្រទេសដែលទទួលរងផលប៉ះពាល់ទាំងនោះ ប្រើប្រាស់វិធានការសមស្របណាមួយ ដូចការបង្កើនប្រព័ន្ធការពារឆ្នេររបស់ពួកគេ។ ដើម្បីឲ្យវាដំណើរការបាន បើទោះបីជា ប្រទេសឧស្សាហកម្មទាំងឡាយគឺត្រូវតែជាអ្នក ដែលផ្តល់ធនធានសំខាន់ៗ ហើយជាមួយគ្នានេះដែរ ពួកវាទាំងនោះត្រូវ តែបានដាក់ឲ្យប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាពផងដែរ។ •










Climate change has accelerated the warming of the ocean and caused a dramatic sea level rise since the beginning of the 20th century.
But the level does not rise at the same pace everywhere in the world; there are regional variations. The sea surface temperature has increased up to 2°C in some places, while the temperature has actually fallen in others. The global sea level rise was on average 20 cm over a period of 100 years.
Satellite measurements from the last 20 years, however, show strong regional variations in sea level increase.

ឆ្នេរសមុទ្រ

# ជីវិតនៅក្នុងតំបន់គ្រោះថ្នាក់

**ទឹកជំនន់ ការហូរច្រោះ និង ការលិចលង់៖ ឆ្នេរសមុទ្ររបស់យើង កំពុងតែរងនូវសំពាធឥតឈប់ឈរ។ ប្រជាជន ដែលរស់នៅតាមតំបន់ឆ្នេរ គឺជាអ្នក ដែលទទួលរង់នូវផលប៉ះពាល់នេះខ្លាំងជាងគេបំផុត ហើយអាត្រាកំណើននៃចំនួនប្រជាជនមានការកើនឡើងជាបន្តបន្ទាប់។**

យោងទៅតាម ការសន្និដ្ឋានរបស់ អង្គការសហប្រជាជាតិ បានឲ្យដឹងថា ចំនួនប្រជាជនសរុបនៅលើសកលលោក នឹងកើនឡើងប្រហែលជា ជិត១០កោដិនៅឆ្នាំ ២០៥០។ ស្របតាមនិន្នាការ ឆ្ពោះទៅរកការធ្វើនគររូបនីយកម្ម នឹងកាន់តែជម្រុញ ឲ្យមានការបង្កើតទីក្រុងធំៗនៅជុំវិញពិភពលោកផងដែរ។ នៅឆ្នាំ ២០៥០ ចំនួន ២០ភាគរយ នៃប្រជាជនសរុប នឹងរស់នៅផ្តុំគ្នាក្នុងទីក្រុងតែមួយហើយពួកគេ នឹងក្លាយជាអ្នកដែលងាយរងគ្រោះជាងគេ។ ថ្មីៗនេះ គេរកឃើញថា ចំនួន ៦២ភាគរយនៃទីក្រុងជាច្រើន មានប្រជាជនរស់នៅជាង ៨លាននាក់ ឬច្រើនជាងនេះ ស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រ។

យើងអាចក្រឡេកទៅមើល ទីក្រុងបាងកក។ ចំនួនប្រជាជនដែលរស់នៅក្នុងរាជធានីប្រទេសថៃបានកើនឡើង ប្រហែល ១០លាននាក់។ ប្រជាជនភាគច្រើន ដែលគេដាក់ឈ្មោះថា វែននីសខាងកើត (Venice of the East) កំពុងរស់នៅក្នុងស្ថានភាពក្រលំបាកក្នុងទីក្រុងបាងកក តាមបណ្តោយប្រព័ន្ធប្រឡាយទឹកដីសណ្តទន្លេចៅប្រះយ៉ា។ ប្រជាជនទាំងអស់នោះកំពុងរស់នៅជាមួយភាពភ័យខ្លាច ដោយសារតំបន់ត្រីកោណ(the Three Sisters)ជាតំបន់ប្រសព្វគ្នារវាងទន្លេបីដែលទទួលរងការជន់លិចខ្លាំងពីទឹកទន្លេ។ នោះគឺជាទីកន្លែងដែលគេហៅថាតំបន់ ប្រសព្វបីមានទឹកជន់ឡើងខ្លាំង ភ្លៀងធ្លាក់ខ្លាំង និងព្យុះទឹកជំនន់ ដែលបណ្តាល មកពីការការកើនឡើងជាលំដាប់នៃបម្រែបម្រួលអាកាសធាតុ។ ពួកគេមានហេតុផល ល្អមួយ ដែលធ្វើឲ្យពួកគេមានការភ័យខ្លាច។ នៅក្នុងឆ្នាំ២០១១ តំបន់ត្រីកោណ (the Three Sisters) បាននាំបញ្ហាទៅដល់ទីក្រុង។ ដោយសារ តែមានខ្យល់មូសុងបោកបក់ខ្លាំង ហើយមានរយៈពេល យូរជាងធម្មតា បណ្តាលឲ្យ ទន្លេបាក់ច្រាំង ហើយស្របពេលនោះដែរ ជំនោរនិទាឃរដូវ បានបង្អាក់ទឹកលំហូរទឹកជំនន់មិនឲ្យហូរចេញទៅទៅក្នុងសមុទ្រវិញបាន។ មនុស្សចំនួន ៦៥៧នាក់ បានបាត់បង់ជីវិត ហើយមានការខូចខាតយ៉ាងធ្ងន់ធ្ងរ។ ឥទ្ធិពលរបស់វាបានប៉ះពាល់រហូតដល់ចម្ងាយរាប់ពាន់គីឡូម៉ែត្រគឺរហូតទៅដល់ការិយាល័យការងាររបស់ពួកបច្ចឹមប្រទេស បណ្តាលឲ្យតម្លៃគ្រឿងឧបករណ៍អេឡិចត្រូនិច(hard drives) របស់កុំព្យូទ័រកើនឡើងមួយទ្វេជាពីរ បន្ទាប់ពីវាត្រូវបានបង្កើតដោយដំណើរ ការឡើងវិញ ដោយសារតែ ៥០ភាគរយនៃឧបករណ៍អេឡិចត្រូនិច(hard drives) ទាំងអស់នោះត្រូវបានបង្កើតឡើងនៅក្នុងតំបន់ទីក្រុងបាងកក។

ទីក្រុងធំៗដែលស្ថិតនៅលើដីតំបន់ទន្លេដីសណ្តទាំងអស់នោះ ដូចជា ទីក្រុងបាងកក ទីក្រុងញូវយ៉ក ទីក្រុងសៀងហៃ ទីក្រុងតូក្យូ និងទីក្រុងចាកាតា គឺជាកន្លែងដែលមានភាពងាយរងគ្រោះ ខ្លាំងជាងគេ។ កន្លែងទាំងអស់នោះ គឺជាតំបន់ដែលមានគ្រោះថ្នាក់ខ្លាំង ជាមួយវិបត្តិសមុទ្រ។ ជាពិសេស ទីក្រុងធំៗទាំងអស់នោះត្រូវបានគំរាមកំហែងដោយ ព្រឹត្តិការណ៍ "១០០ឆ្នាំ" ដូចជាការលិចលង់យ៉ាងធ្ងន់ធ្ងរ ខុសប្លែកពីធម្មតា។ នៅក្នុងតំបន់ទន្លេដីសណ្តរ ការគំរាមកំហែង ដ៏ធំបំផុតជាច្រើន បានកើតឡើងចំពោះទីក្រុង ជាមួយគ្នានឹងសេចក្តីវិនាសដែលមិនអាចជៀសផុត។ បន្ថែមពីលើតំបន់ត្រីកោណ ( the Three Sisters ) ការគំរាមកំហែងដ៏ធំមួយទៀតនោះគឺ ការកើនឡើងនៃការស្រុតចុះ មានន័យថា ដីនៅខាងក្រោមទីក្រុង ដែលទទួលរងឥទ្ធិពលទាំងអស់នោះ គឺកំពុងតែលិចចូលទៅក្នុងទឹក។ ទីក្រុងបាងកក ទីក្រុងសៀងហៃ និង ទីក្រុងញូវអរឡែន បានលិចចុះ ប្រហែលជម្រៅ៣ម៉ែត្រ នៅក្នុងសតវត្សទី២០។ ទីក្រុងតូក្យូ និង ទីក្រុងចាកាតាបានលិចចុះ ជម្រៅ៤ម៉ែត្រ។ ផ្នែកមួយចំនួននៃទីក្រុងទាំងនោះ គឺស្ថិតនៅក្រោម នីវ៉ូទឹកសមុទ្រទៅហើយ។ ការស្រុតចុះ គឺជាកត្តាធម្មជាតិ នៅតាមតំបន់ដីសណ្តរ តែ កំនើនខ្លាំងនៃល្បឿនរបស់វាគឺកំពុងតែបណ្តាលឲ្យក្លាយទៅជាគ្រោះមហន្តរាយត្រឡប់ទៅវិញ ដោយសារតែកត្តាធម្មជាតិនេះ។ និស្សារណកម្មពីទឹកក្រោមដី និង ភាពហាប់ណែនរបស់ដី ដែលកើតពីទំងន់នៃការផ្ទុះឡើងរបស់សំណង់ យ៉ាងគគ្រឹកគគ្រេង កំពុងតែប្រឈម នឹងភាពអន្តរាយ។ ទីក្រុងធំៗ កំពុងបន្តស្រុតលិចដែលក្នុងករណីខ្លះវាអាចមានល្បឿន លឿនជាងម្តែដងធៀបទៅនឹងកម្រិតនីវ៉ូទឹកសមុទ្រ ដែលកំពុងតែកើនឡើង។ នៅក្នុងសតវត្សទី២០ ការកើនឡើងជាមធ្យមរបស់នីវ៉ូទឹកសមុទ្រនៅលើសកល មានចំនួនប្រមាណជាង ២០សង់ទីម៉ែត្រ។

កត្តាបន្ថែមមួយទៀត ដែលជំរុញល្បឿននៃការស្រុតចុះនេះ គឺទំនប់ទឹក ដែលត្រូវបានសាងសង់ លើទន្លេធំៗជាច្រើន ដែលមានឥទ្ធិពលលើដីសណ្តរ។ ទំនប់ទឹកទាំងនោះ ទប់ខ្សាច់ និងកករ ដែលជាធម្មតា ពួកវាត្រូវបានហូរនាំទៅបំពេញក្នុងសមុទ្រ។ ការហូររបស់ដីល្បាប់នេះហើយ ដែលបានបង្កើតតំបន់ដីសណ្តរ តាំងពីដំបូង អស់រយៈពេល ជាងរាប់រយពាន់ឆ្នាំមកនេះ។ បច្ចុប្បន្ន ក្នុងករណីខ្លះ លំហូររបស់ដីល្បាប់ មានចំនួនតែ៥០ភាគរយប៉ុណ្ណោះ ដែលអាចហូរចាក់ទៅដល់តំបន់ដីសណ្តរបាន។ ដោយសារតែ ទំនប់ទឹក និងវិធានការណ៍បន្ថែមលើបញ្ញត្តិទន្លេ មិនមានវិធីណា ដែលអាចធ្វើឲ្យ តំបន់ដីសណ្តរ អាចបំពេញខ្លួនសារជាថ្មីនោះទេ។ តំបន់ដីសណ្តរទាំងនោះ កំពុងតែបាត់ខ្លួនបន្តិចម្តងៗ ស្របពេលដែលជំនោរសមុទ្រ កំពុងតែនាំយកដីខ្សាច់ ទៅជាមួយវាជានិច្ច។

ក្រុមអ្នកវិទ្យាសាស្រ្ត និង អ្នករៀបចំនគររូបនីយកម្ម កំពុងតែពិភាក្សាគ្នា ថាតើទីក្រុង ទាំងនោះ អាចត្រូវបាន គាំពារក្នុងរយៈពេលវែងបានដែរឬទេ? ឬក៏ពួកវានឹងត្រូបានគេបោះបង់ ចោលក្នុងពេលណាមួយ? បើទោះបី ពួកវាកំពុងតែរីកលូតលាស់ខ្លាំងយ៉ាងណាក៏ដោយ។ វា គឺជាបញ្ហាប្រឈម ដ៏ធំមួយសម្រាប់ទីក្រុង ដែល ទទួល រងឥទ្ធិពលយ៉ាងធ្ងន់ធ្ងរ ដូចជា ទីក្រុងតូក្យូ ទីក្រុងញូវអរឡែន និង

Endangered River Deltas




1. Megacities grow larger and larger.
2. Megacities sink because of soil compaction and the extraction of groundwater, oil, and natural gas.
3. Destruction of natural coastal protections like mangroves.
4. Rising sea levels.
5. Soil salinization caused by seawater.
6. Reduced sediment deposits in deltas due to construction of dams, etc.
7. Less sediment leads to stronger erosion.
8. Storms from the sea magnify incidents of flooding.
9. Strong precipitation (monsoons) leads to river flooding and to rising water levels in the deltas.

## Megacities: Dangerous Developments




Many megacities are especially threatened by flooding because they are located in places where several risk factors coincide.

ទីក្រុងញូវយ៉ក ដែលពួកវាត្រូវបានវាយប្រហារ ដោយព្យុះខ្យាច់ នៅឆ្នាំ ២០១២។ ទីក្រុងមានដ៏ស្តុកស្តម្ភទាំងអស់នេះ ត្រូវបានធ្វើវិនិយោគលុយរាប់រយកោដិ ទៅលើប្រពន្ធ័ការពារទំនើបៗ និងការសាងសង់សំណង់ ដែលអាចការពារ ការគំរាមកំហែងពីសមុទ្រ។ ប៉ុន្តែ ប្រទេសកំពុងអភិវឌ្ឍជាច្រើនមានកង្វះ ខាតធនធានហិរញ្ញវត្ថុ ឬ ការយល់ ដឹងសំខាន់ៗ សម្រាប់ទប់ ស្កាត់ នឹងបញ្ហា ប្រឈមជាក់ស្តែងនេះ។

ការពិចារណានោះគឺ ថាតើ មានតែប្រទេសអ្នកមានទេឬ ដែលអាចមាន លទ្ធភាពធ្វើប្រព័ន្ធការពារទាំងអស់នោះ ដើម្បីអាចរស់នៅបាន ហើយដែលនេះ វាគឺជាបញ្ហាសកល? នៅពេលដែលទីក្រុងបាងកក ត្រូវបានវាយប្រហារដោយ គ្រោះទឹកជំនន់ រាជរដ្ឋាភិបាលថៃ បានសាងសង់ របងការពារប្រវែង ៧៧ គីឡូម៉ែត្រ យ៉ាងវែងពីបាវខ្សាច់។ វាបានចែក មាតុធានី ទៅជាតំបន់ពីរ តំបន់ជួរមុខទំនប់ និងជួរក្រោយទំនប់ ហើយបែងចែក តំបន់ការការពារ និងតំបន់គ្មានការការពារដាច់ពីគ្នា។ នៅពេលដែល ទឹកជំនន់វាយប្រហារ ប្រជាជនដែលនៅខាងក្រៅទំនប់ បានព្យាយាមទំលាយរបាំង ដើម្បីធ្វើឲ្យមាន ផ្លូវទឹកហូរចេញ។ អំពើហឹង្សាប្រឈមមុខគ្នា ដែលបានផ្ទុះឡើង បង្ហាញឲ្យឃើញ ពី សក្តានុពលសម្រាប់បញ្ហានានាទៅពេលពេលអនាគត។ វាបានកើតឡើង ដោយសារតែ ជញ្ជាំង ម៉ាស៊ីនបូមទឹក ហើយទំនប់ទាំងអស់នោះ ជាធម្មតាសម្រាប់ការពារកន្លែងទីប្រជុំជនមានមនុស្សកុះករតែប៉ុណ្ណោះ។ សម្រាប់ហេតុផលជាច្រើននៅក្នុងសង្គមតែមួយដូចនេះការសាងសង់ទំនប់ទឹក បែងចែកទីក្រុង និងតំបន់ មិនអាចជាមធ្យោបាយ តែមួយគត់នោះទេ។

រលកយក្សស៊ូណាមិ (Tsunami) ក៏ជាការគំរាមគំហែងមួយដ៏ធំដែរ វា មិនត្រឹមជះឥទ្ធិពលលើទីក្រុងធំៗនោះទេប៉ុន្តែរួមទាំងប្រជាជន និង លំនៅដ្ឋាន នៅតាមតំបន់ឆ្នេរ ដែលងាយទទួលរងគ្រោះថ្នាក់ផងដែរ។ ឱកាសនៃការកើតមានរបស់រលកយក្សស៊ូណាមី (Tsunami) គឺមានតិចតួច តែការជះឥទ្ធិពលរបស់វាគឺមហិមា។ ឧទាហរណ៍ជាក់ស្តែងពី គ្រោះមហន្តរាយ របស់វា នៅតាមបណ្តយឆ្នេរមហាសមុទ្រឥណ្ឌានាកាលពីឆ្នាំ ២០០៤ និង នៅតាមបណ្តោយឆ្នេរសមុទ្រភាគខាងលិចរបស់ជប៉ុននៅក្នុងឆ្នាំ ២០១១។

សម្រាប់ទីក្រុងធំៗទាំងអស់ដែលរងគ្រោះ គួរតែត្រូវបានទីក្រុងផ្សេងៗ និងសហគមន៍សកល ចូលរួមជាមួយគ្នាធ្វើកិច្ចពិភាក្សា៖ ថា តើនរណា ដែលយើងគួរត្រូវបានទទួលការការពារ? តើយើងអាចការពារអ្វីបានខ្លះ? តើអ្វីទៅអាចធ្វើឲ្យមានចីរភាព? តើអ្វីទៅដែលត្រឹមត្រូវយុត្តិធម៌? ស្ថានការណ៍ នៅលើតំបន់ឆ្នេរ តែងតែផ្លាស់ប្តូរជានិច្ច ហើយផែនការរបស់យើង ត្រូវតែ មានការពិនិត្យ និងរៀបចំឡើងវិញ ម្តងហើយម្តងទៀតផងដែរ។ តម្រូវការ និងបទពិសោធន៍ ប្រជាជនទាំងអស់ គឺត្រូវធ្វើការចុះស្រាវជ្រាវស្ទង់មតិ និងត្រូវបានពិចារណា ហើយវិធានការណ៍ថ្មីៗ ត្រូវតែបានបង្កើតឡើងដោយ យកចិត្តទុកដាក់ឲ្យមានភាពចុះសម្រុងជាមួយនឹងធម្មជាតិ។ នៅក្នុងករណីខ្លះ វាអាចមានន័យថា យើងត្រូវតែលះបង់ដីតំបន់ខ្លះឲ្យសមុទ្រ ដើម្បីការពារវា នៅកន្លែងផ្សេងទៀត។ •

## Increased Flooding on the East Coast of the US




Local flooding has greatly increased along the entire east coast of the United States. The water does not rise very high and quickly recedes—but it also gradually destroys neighborhoods and infrastructure, causing residents to move away and property prices to fall.

## Emerging Giant—A Tsunami Races across the Ocean




Tsunamis are also a threat to the growing coastal populations.

## ការក្រឡេកមើលទៅក្នុងអតីតកាល

# ការទាញយកផលប្រយោជន៍ និង តំបន់អភិរក្ស

រុក្ខជាតិ និងសត្វជាច្រើន ដែលកំពុងតែរស់នៅ ក្នុងវាលរហោឋាន របស់មហាសមុទ្រ ហើយអ្វីៗទាំងនោះ ដែលយើងចង់រក្សាទុក នៅក្នុងតំបន់អភិរក្សសមុទ្រ គឺគ្រាន់តែ ជាចំណែកមួយនៃអ្វី ដែលធ្លាប់បានលូតលាស់នៅក្នុងសមុទ្រប៉ុណ្ណោះ។ ដើម្បីយល់ដឹងពីអ្វីៗ ដែលយើងបានបាត់បង់ ហើយអ្វីដែលយើង ប្រហែលជាអាចស្រោចស្រង់វិញបាន យើងត្រូវដឹងថា តើវាធ្លាប់មានសាវតាបែបណា?

Declining Populations* (Percentage Change)




បើសិនជា យើងបូកបញ្ចូលគ្នាទាំងអស់ គ្រប់ផ្នែក និងប្រភេទនៃតំបន់អភិរក្ស វាមានទំហំតែ ៣.៥ភាគរយប៉ុណ្ណោះ នៃមហាសមុទ្រទាំងមូលដែលកំពុងតែត្រូវបានការពារ។ ហើយមានតែ ១.៦ភាគរយប៉ុណ្ណោះ គឺត្រូវបានការពារយ៉ាងតឹងរឹង និងពេញលេញ ដូចជាសមុទ្រ រ៉ូស (Ross) ជាដើម។ វាត្រូវបានគេចាត់ទុកជា តំបន់ទំនេរនៅឆ្នាំ ២០១៧ សមុទ្រនេះ ក្លាយជាតំបន់អភិរក្សសមុទ្រដ៏ធំជាងគេនៅក្នុងពិភពលោក ។សម្រាប់រយៈពេល ៣៥ឆ្នាំទៅមុខទៀត រាល់ការទាញយកផលប្រយោជន៍ទាំងអស់លើវា ត្រូវបានគេហាមឃាត់ ទៅលើទំហំជាង ៧០ភាគរយនៃតំបន់នេះ ហើយអ្វីដែលនៅសល់ប្រហែលជាត្រូវបានគេប្រើប្រាស់ សម្រាប់តែគោលបំណង នៃការស្រាវជ្រាវតែប៉ុណ្ណោះ។ អង្គការបរិស្ថាន និងអ្នកវិទ្យាសាស្ត្រជាច្រើន ទាមទារថាចន្លោះពី ២០ ទៅ ៥០ភាគរយ នៃមហាសមុទ្រ គឺត្រូវចាត់ទុកជាតំបន់អភិរក្ស។ គោលដៅរបស់វា គឺមិនមែនដើម្បីតែរក្សារបស់ទាំងនោះ ដូចអ្វីដែលពួកវាធ្លាប់មាននោះទេ បើទោះបីជានៅក្នុងតំបន់អភិរក្ស ក៏ពួកយើងបានមើលឃើញពីការកើតមាននៃចំណែកតូចៗមួយចំនួននៃជីវចម្រុះ ដែលធ្លាប់កើតមានឡើងតែប៉ុណ្ណោះ តែពួកយើងចង់ឲ្យជីវិត ទាំងអស់នោះកកើតឡើងវិញ។

អស់រយៈពេលរាប់រយឆ្នាំមកហើយ អ្នកអាចចាប់ត្រីនៅកន្លែងជាច្រើនដោយគ្រាន់តែ ប្រើដៃ និងសំណាញ់។ គ្រាន់តែ ៥០០ឆ្នាំមុន ត្រីបាឡែនប្រផេះ និង ត្រីបាឡែនភិយ (Right Whale) ដែលសាច់របស់វា មានតម្លៃនៅក្នុងទីផ្សារគឺជាមុខសញ្ញាធម្មតា នៅក្នុងសមុទ្រខាងជើង។ បីបួនរយឆ្នាំមុន អណ្តើកសមុទ្របានរស់នៅពាសពេញកោះការីបៀន (Caribbean)។ វាត្រូវបានគេនិយាយថា មនុស្សនៅលើកោះ ការីបៀន (Caribbean) Caribbean តែងតែរអ៊ូថា ពួកគេមិនអាចគេងលក់ បានទេនៅពេលយប់ ដោយសារតែសំលេងរំខានរបស់សត្វធំៗទាំងអស់នោះ ដោយពួកវាតែងតែបុកជាមួយគ្រោងនាវា។ នៅក្នុងសតវត្សទី១៧ សត្វអណ្តើកបៃតងគឺមាននៅមានចំនួន ៩០លានក្បាល។ អ្នកខ្លះបានដាក់ឈ្មោះវាថា អណ្តើកស៊ុប ដោយសារតែ ពួកវាត្រូវបានគេយកធ្វើជា សាច់ស្រស់ដ៏សំបូរបែបសម្រាប់អ្នកដើរ សមុទ្រ និងធ្វើជាគ្រឿងលម្អ សំរាប់គ្រួសារអ្នកមានស្តុកស្តម្ភ។ ប៉ុន្តែបច្ចុប្បន្ននេះ វានៅមានចំនួនតែ ៣០០០០០ក្បាល តែប៉ុណ្ណោះ នៅលើកោះ ការីបៀន (Caribbean) ។

មិនគ្រាន់តែចំនួនគ្រួសាររបស់វាច្រើនប៉ុណ្ណោះទេ តែខ្លួនរបស់វាក៏ធំដែរ។ នៅដើមសតវត្សទី ២០ អ្នកនេសាទ ចាប់បានប្រភេទត្រី Sturgeons មានប្រវែងជាង ៣ម៉ែត្រ នៅក្នុងប្រទេសអាឡឺម៉ង់។ ត្រីប្រប៉ែល មានទំងន់ ២២០០ គីឡូក្រាម ត្រូវបានគេចាប់បាន នៅឯឆ្នេរសមុទ្រខាងកើតរបស់សហរដ្ឋអាមេរិច។ តែសព្វថ្ងៃនេះ ត្រីធំៗ គឺមិនសូវមានទៀតទេ។ ហេតុផលនោះ គឺមកពីឧស្សាហកម្មត្រីខ្នាតធំ។ តីត្រូវបានគេនេសាទយកទៅអស់ មុខពេលដែលពួកវាអាចមានឱកាសដើម្បីលូតលាស់ធំធាត់។

វាគឺជាមេរៀនចាស់ ដែលពួកយើងរៀនយ៉ាងយឺតៗ។ ២០០០ឆ្នាំមុន ជនជាតិរ៉ូម បាននេសាទត្រី បែបជំនួញបាន ១៥០ប្រភេទ ផ្សេងៗពីគ្នា។ ហើយការធ្វើអាណានិគមលើដែនដីថ្មី នាសតវត្សទី ១៦ បានបង្កើតអោយមានផលវិបាកយ៉ាងខ្លាំងមិនមែនសម្រាប់តែ សត្វអណ្តើកបៃតងនោះទេ។ ប្រវត្តិសាស្ត្រនៃការនេសាទត្រីបាឡែន ក៏បានធ្វើជាមេរៀន ដ៏ល្អមួយរួចទៅហើយ។ អ្នកនេសាទត្រីបាឡែន បាននិយាយថា ត្រីបាឡែនភិយ (Right Whale) ត្រូវបានគេហៅឈ្មោះបែបនេះ

Living Memory—Old Fishermen Tell Their Tales




The Gulf of California for an old fisherman (1940s) The Gulf of California for a middle-aged fisherman (1970s) The Gulf of California for a young fisherman (1990s)

## Marine Protected Areas—Space to Recover




ដោយសារតែវាជាប្រភេទត្រីបាឡែនដែលរស់នៅក្នុងលក្ខខណ្ឌល្អសម្រាប់ការនេសាទ ដែលរស់នៅតាមឆ្នេរ និងហែលយឺតៗ ហើយពួកវា គឺងាយស្រួលចាប់។ ពួកវាអណ្តែតឡើងលើផ្ទៃទឹកនៅពេលដែលស្លាប់ វាបានផ្តល់ផល ជាខ្លាញ់ត្រីបាឡែនដ៏មានតម្លៃជាច្រើន ពេលដែលត្រូវបំពងក្នុងខ្លាញ់។ មនុស្សបានចាប់ផ្តើមប្រមាញ់ពួកវានៅប្រហែលជាកាលពី ១០០០ឆ្នាំមុខគ.ស។ ដោយសារតែ កប៉ាល់របស់ពួកគេមានភាពធន់ខ្លាំងជាមួយនឹងសមុទ្រ ពួកគេបានតាមចាប់ត្រីបាឡែន ដល់ក្នុងមហាសមុទ្រទៀត។ នៅសតវត្សទី ១៨ និង ១៩ ចំពោះទំហំនៃការនេសាទត្រីបាឡែន រ៉ាយ (Right Whale) ត្រូវបានគេតាមប្រម៉ាញ់ តាំងពីភាគខាងត្បូងមហាសមុទ្រអាត្លង់ទិច ដល់ភាគខាងជើងមហាសមុទ្រប៉ាស៊ីភិច។ ចំពោះវិបាកបស់វាវិញនោះ គឺថាត្រីបាឡែនរ៉ាយ (Right Whale) គឺស្ទើរតែផុតពូជទៅហើយ នៅដើមសតវត្សទី ២០។

មនុស្សជាតិ បានកើនឡើងគួរអោយគត់សំគាល់ ជាពិសេសជាមួយប្រវត្តិថ្មីៗនេះ។ ការគោរពរបស់យើងចំពោះធម្មជាតិ គឺមានភាពមិនស៊ីចង្វាក់គ្នាទាល់តែសោះ។ ប្រភេទសត្វទាំងមូល ត្រូវបានបូជាសម្រាប់ម៉ូតទាន់សម័យថ្មីៗ និងនិន្នាការផ្សេង។ មនុស្សបានគំទេចអណានិគម របស់សត្វស្លាបសមុទ្រទាំងមូល ដើម្បីបោចយកស្លាប ពួកវា សម្រាប់ធ្វើម្ហូកទាន់សម័យរបស់នារីៗ។ ហើយរឿងនិទាននៃការធ្វើម្ហូបខ្លះៗ គឺស្តាប់ទៅមានមន្ទិលសង្ស័យនាពេលសព្វថ្ងៃនេះ។ តើអ្នកអាចស្រម៉ៃមើលបានទេថា បង្កង គឺពិតជាមានតំលៃថោកខ្លាំងណាស់ នៅឯទីក្រុងប៊ូស្តុននៅចុងឆ្នាំ ១៨៩០ ដែលវាត្រូវបាន ធ្វើជាម្ហូបសម្រាប់អ្នកនៅក្នុងគុក។ ក្នុងពេលបច្ចុប្បន្នពួកយើងជារឿយៗមើលឃើញ មហាសមុទ្រថា ជាផ្សារទំនើបគ្មានកំណត់។

តែបើយើងគិតថា មហាសមុទ្រនៅតែពោរពេញទៅដោយជីវិតទៀតនោះ ពួកយើងកំពុង តែបោកប្រាស់ខ្លួនឯងហើយ។ អ្វីៗដែលពួកយើងព្យាយាមថែរក្សា នឹងធ្វើឲ្យដូចដើមវិញ នៅក្នុងតំបន់អភិរក្ស គឺគ្រាន់តែជាអ្វីដែលនៅសល់ពីកំណប់ដ៏អស្ចារ្យ និងភាពចម្រុះ ដែលធ្លាប់កើតមានតែប៉ុណ្ណោះ។ យ៉ាងណាពួកយើងក៏ឆ្លាតជាងមុនដែរ ដែលពួកយើងកម្រប្រម៉ាញ់ថនិកសត្វសមុទ្រធំទៀតដែរ។ វាគឺជាការចាប់ផ្តើម តែវានៅមិនទាន់គ្រប់គ្រាន់ទេ។ ឈ្លើងសមុទ្រ គឺនៅតែត្រូវថ្លៃ ហើយជាប្រណិតភាពមួយនៅក្នុងទ្វីបអាស៊ី។ ចាប់តាំងពីដើមរហូតដល់ ៥០ឆ្នាំមុន វាគឺត្រូវបានគេចាប់នៅតែក្នុងតំបន់ប៉ុណ្ណោះ។ នៅក្នុងឆ្នាំធ្វើអន្តរាគមន៍ បើទោះបីជា ឧស្សាហកម្មឈ្លើងសមុទ្រ បានរីករាលដាលចូលទៅក្នុងមហាសមុទ្រទាំងមូលប៉ុន្តែ ពួកវា គឺមិនគួរឲ្យស្រឡាញ់ដូចជាកូនភេសមុទ្រទេ។ ដូច្នេះហើយពួកវា គឺមិនត្រូវបានការពារ យ៉ាងល្អិតល្អន់ដែរ។ ហើយដោយសារតែ ប្រវត្តិសាស្រ្តកំពុងតែគំរាម ចង់ចាប់ផ្តើមឡើងវិញម្តងទៀត ប្រហែលជាថ្ងៃណាមួយ កូនចៅរបស់ពួកយើង នឹងក្រឡេកមើលម្តងទៀតទៅលើឈ្លើងសមុទ្រដែលបានបាត់បង់ ជាមួយនឹងភាពក្រៀមក្រំដូចគ្នាដែរ ដែលពួកយើងឥឡូវនេះមានអារម្មណ៍ចំពោះការបាត់បង់នៃត្រីបាឡែន។ •

## Expansion of the Hunt




Southern right whales were hunted in the southern hemisphere for around 200 years. The historical peak population was approx. 80,000 whales. Today, only 7,500 remain. The global sea cucumber catch has risen from 2,300 to 30,500 metric tons in just 60 years (1950–2006).

ការគ្រប់គ្រងមហាសមុទ្រ

# តើមហាសមុទ្រជារបស់នរណា?

អស់រយៈពេលរាប់ពាន់ឆ្នាំមកនេះ មនុស្សបានទាញយកផលប្រយោជន៍ពីសមុទ្រតាមរយៈការនេសាទត្រី និងធ្វើជំនួញ។ ច្រើនសតវត្សមកនេះ សង្គ្រាមជាច្រើនបានកើតឡើង ហើយអ្នកឈ្នះ បានទាមទារសិទ្ធិទៅលើសមុទ្រ និងទាញផលប្រយោជន៍ពីវា។ ជម្លោះជាច្រើននៅតែបន្តកើតមានរហូតមកដល់សព្វថ្ងៃនេះ។

ប៉ុន្តែ វាមិនមែនគ្រាន់តែបញ្ហានៃទំនាក់ទំនងការដឹកជញ្ជូនតាមផ្លូវសមុទ្រប៉ុណ្ណោះទេ។ មូលហេតុនៃជម្លោះអន្តរជាតិក្នុងពេលបច្ចុប្បន្ន គឺស្ថិតនៅក្នុងភាពមិនច្បាស់លាស់។ ដំណោះស្រាយនៃជម្លោះជាច្រើន គឺពាក់ព័ន្ធជាមួយការពង្រីកដែនសមុទ្រ និងតំបន់សេដ្ឋកិច្ច ដើម្បីធានាសិទ្ធផ្តាច់មុខ ទៅលើអ្វីដែលគេហៅថា ធនធានសមុទ្រគ្មានជីវិត ដូចជា រ៉ែ ឥន្ធនៈហ្វូស៊ីលដ៏មានតំលៃ ដែលបានកប់នៅក្រោមបាតសមុទ្រ។ ពួកវាគឺជា "ដែនដី" របស់សមុទ្រ។ វាដូចជាមិនសូវសមហេតុផលមែនទេ? វាមិនមែនទេ បើសិនជាយើងក្រឡេកទៅមើលកន្លែង ដែលផ្ទៃដីចាប់ផ្តើមកកើតឡើង ហើយនឹងកន្លែងដែលវានឹងបញ្ចប់។

មូលដ្ឋានគ្រឹះ គឺនៅក្នុងសន្ធិសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់ដែនសមុទ្រ ឆ្នាំ ១៩៨២ (UNCLOS 1982)។ ក្នុងសន្ធិសញ្ញាបានចែងថាប្រទេសមួយ អាចពង្រីកដែនដីសមុទ្របន្ថែមចម្ងាយ ១២ម៉ាយល៍ (ប្រហែល ២២.២៥ គីឡូម៉ែត្រ) ពីតំបន់ឆ្នេរ ដែលស្ថិតនៅក្នុងដែនអធិបតេយ្យសមុទ្ររបស់ខ្លួន។ បន្ថែមពីនេះទៅទៀត យើងអាចទាញយកផលពីសមុទ្រក្នុងទំហំផ្ទៃទឹកចម្ងាយ ២០០ម៉ាយល៍ (ប្រហែល ៣៧០.៤គីឡូម៉ែត្រ)លាតសន្ធឹងពីតំបន់ឆ្នេរ បង្កើតជាតំបន់សេដ្ឋកិច្ចផ្តាច់មុខបាន។ច្បាប់នេះក៏អាចអនុវត្តបានដូចគ្នា ក្នុងចម្ងាយ ២០០ម៉ាយល៍ (ប្រហែល ៣៧០.៤ គីឡូម៉ែត្រ) ពីមាត់សមុទ្ររហូតដល់ ដែលតំបន់ទឹករាក់ (Continental shelf)។ ធនធានសមុទ្រនៅតំបន់នោះត្រូវបានទាញយកផលប្រយោជន៍ពីប្រទេសខ្លួនឯងតែប៉ុណ្ណោះ។ ក្នុងករណី ប្រទេសនោះ អាចប្រើវិទ្យាសាស្ត្រមកបង្ហាញថា Continental Shelf របស់វា អាចលាតសន្ធឹងឆ្ងាយ ជាងអ្វីដែលបានកំណត់ហើយបើស្ថានភាពភូមិសាស្ត្រអាចតភ្ជាប់គ្នាបាន ទៅដល់តំបន់ដីគោក ប្រទេសនោះមានសិទ្ធិផ្តាច់មុខទៅលើធនធានដែលមាននៅទីនោះផងដែរ។ ការទាមទារអធិបតេយ្យភាពនេះ ត្រូវបានរួមបញ្ចូលទាំងបណ្តាកោះទាំងអស់ ប៉ុន្តែមិនអាចមានសិទ្ធិទៅលើថ្មគ្រួស ឬផ្ទាំងថ្មដទៃផ្សេងៗ ដែលដុះចេញនៅលើផ្ទៃដី និងទឹកនោះទេ។

វាពិតជាគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ សម្រាប់កោះដែលគ្មានជីវិតរស់នៅ ដូចជាកោះហ៊ើដ (Heard Island) និងប្រជុំកោះម៉ាកដូណាល់ (McDonald Islands) ជាដើម។ ពួកវាទាំងនោះ គឺជាកោះតូចៗ ដែលមានចម្ងាយ ១០០០គីឡូម៉ែត ពីភាគខាងជើង នៃទ្វីបអង់តាកទិកខាងកើត។ អរគុណដល់ពួកវាទាំងនោះ ដែលប្រទេសអូស្ត្រាលីបានធានាការពារ ការកេងប្រវ័ញ្ចពីក្នុងភូមិសាស្ត្រទាំងនេះមានទំហំប្រមាណជាង ២.៥លានម៉ែត្រការ៉េ។ នេះដោយសារតែ កោះទាំងនោះ ស្ថិតនៅក្នុងតំបន់សមុទ្រ ក័រហ្គឡែន ផ្លាតូ ( Kerguelen Plateau) ដែលជួរភ្នំ ដ៏ធំមួយលាតសន្ធឹងជាង ២០០០គីឡូម៉ែត្រ។ ក្នុងបច្ចុប្បន្នភាពនេះ ប្រទេសអូស្ត្រាលីទាមទារ សិទ្ធិផ្តាច់មុខក្នុងការប្រមូលផលពី កោះទាំងអស់នោះ។ ប៉ុន្តែ នៅក្នុងសន្ធិសញ្ញាបានដាក់ល័ក្ខខណ្ឌកំណត់សម្រាប់ការងារនេះដែរ ក៏ប៉ុន្តែសិទ្ធិរបស់គេនៅតែអាចពង្រីកលាតសន្ធឹងរហូតទៅដល់ចម្ងាយ៣៥០ម៉ាយល៍ (ប្រហែល ៦៤៨.២ គីឡូម៉ែត្រ)។

សន្ធិសញ្ញាស្តីពីច្បាប់សមុទ្រ (UNCLOS 1982) បានគេកំណត់ ធ្វើជារដ្ឋធម្មនុញ្ញនៃមហាសមុទ្រ ហើយត្រូវបានគេប្រើប្រាស់ សម្រាបកាត់ក្តីប្រកបដោយសន្តិវិធី ពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ភាគីនៃរដ្ឋទាំងអស់ ដែលនៅមានសភាពក្មេងខ្ចីនៅឡើយ។ យន្តការនេះគឺសម្រាប់តំបន់ទាំងអស់នៃ ocean floor ដែលលាតសន្ធឹងនៅក្រៅតំបន់អធិបតេយ្យភាព និងក្រៅសិទ្ធិទាញយកផលប្រយោជន៍របស់ប្រទេសនោះ នៅក្នុងអត្ថន័យនេះ "តំបន់" នៅក្នុងភាសាផ្លូវ

How the Lawyers Think—Maritime Zones and the International Law of the Sea




Today, humanity's inheritance is solely limited to the mineral resources of the parts of the seafloor that lie beyond national jurisdictions ("the Area"), which is administered by the Seabed Authority.
The UN Convention on the Law of the Sea (UNCLOS), together with its existing implementing conventions, defines the framework for ocean governance. The regional fisheries management organizations (RFMO) organize the cultivation of the fish stocks in the high seas as well as the trans-territorial and far-ranging fish stocks in the Exclusive Economic Zones (EEZ).

The International Community Is Losing Ground—As Individual Countries Gain It




The expansion of coastal countries' exclusive economic zones (dark green) into the area of the outer continental shelf (orange) reduces the international area. Any gain for an individual country is a loss for the community of nations. 57 percent of the sea floor is already partitioned. Only 43 percent of humanity's shared inheritance remains.

ការរបស់អង្គការសហប្រជាជាតិគឺសំដៅទៅដល់ទស្សនៈ នៃ "ការចែករំលែកបេតិកភណ្ឌប្រកបដោយភាពមនុស្សធម៌"។ វាត្រូវបានគេត្រៀមជានិច្ចដើម្បីធានាឲ្យប្រាកដថាបរិស្ថានគឺត្រូវបានការពារ ហើយប្រទេសកំពុងអភិវឌ្ឍទាំងអស់ក៏ត្រូវចែករំលែកជាមួយប្រទេសអភិវឌ្ឍដែរ។

ពាក្យសំដីដ៏មានទម្ងន់ទាំងអស់នេះ ពេលខ្លះ លទ្ធផលដែលទទួលបានគឺទន់ខ្សោយ។ នៅពេល ដែលប្រទេសមួយ អាចពង្រីកតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួនដោយស្របច្បាប់ វាក៏កាត់បន្ថយការចែករំលែកសិទ្ធិទទួលមរតកសម្បត្តិទៅអ្នកផ្សេងដែរ។ ពិចារណាទៅលើករណី របស់ប្រទេសណ័រវេដែលបានធ្វើការគ្រោងទុកយក តំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួនចម្ងាយ ៥០០០០០គីឡូម៉ែត្រការ៉េហើយក៏ត្រូវអរគុណ ដល់ភាពជាម្ចាស់របស់វាទៅលើកោះ ប៊ូវេត (Bouvet) ដែលជាកោះតូចមួយគ្របដណ្តប់ដោយទឹកកក ហើយជួបកង្វះខាតទឹកសាបសម្រាប់ប្រើប្រាស់ ដែលស្ថិតនៅ ភាគខាងត្បូងមហាសមុទ្រអាត្លង់ទិចចម្ងាយ ២៦០០គីឡូម៉ែត្រ ពីឆករបស់ឆ្នេរហ្គុដហូប ( Good Hope)។ ប្រទេសបារាំង ក៏បានពង្រីកវិសាលភាពរបស់ខ្លួនផងដែរ និងធ្វើការ អរគុណដល់កោះចំណុះទាំងអស់របស់វាហើយវានៅតែជា ប្រទេសដែលមានសក្តានុពលអស្ចារ្យនៅពេលដែល គិតដល់រតនសម្បត្តិដែលមានស្តុកទុកនៅក្នុងស្រទាប់មហាសមុទ្រ។

នៅក្នុងការបង្កើតសំណើរទាំងអស់នេះ គណៈកម្មការអង្គការសហប្រជាជាតិដើរតួរយ៉ាងសំខាន់ លើការដាក់កម្រិតទៅលើដែនតំបន់ទឹករាក់ (Continental Shelf)។ យើងអាចនិយាយថា រដ្ឋដែលមានសិទ្ធិ លើវត្ថុធាតុដើម ពេលខ្លះពួកគេគ្រាន់តែសម្គាល់ឃើញពីឱកាសសេដ្ឋកិច្ចមួយផ្នែក ឬគ្រាន់តែធ្វើការប៉ាន់ស្មានពោលគឺធ្វើទៅទាំងផ្សងព្រេងមិនច្បាស់លាស់អំពីទ្រព្យសម្បត្តិទាំងអស់នោះនៅពេលអនាគតទេ។ វាមិនមែនត្រឹមតែសំដៅទៅលើ ឥន្ធនៈហ្វូស៊ីល រ៉ែ លោហធាតុ និងថាមពល ដែលបានមកពីការគ្រប់គ្រងរបស់ពួកវានោះទេ។ ទាក់ទងទៅនឹងការបង្កើតយុទ្ធសាស្រ្តផលប្រយោជន៍ជាសកលនៃប្រទេសនីមួយៗ

នៅក្នុងការពង្រីក ដែនឥទ្ធិពលជាផ្លូវការរបស់ខ្លួនផងដែរ។ ចំណែក "ទីតាំង" ដែលនៅសល់មិនទាន់មានការកាន់កាប់ គឺកាន់តែតូចទៅៗ។ វាបានថយចុះពីជាង ៧០ភាគរយនៃបាតសមុទ្រ មកសល់ត្រឹមតែ ៤៣ភាគរយប៉ុណ្ណោះ។ ៥៧ភាគរយនៃទំហំបាតសមុទ្រ ត្រូវបានចែកជាចំណែកៗទៅហើយ។ ហើយដោយសារតែ ដែនអន្តរជាតិ កំពុងតែរួមតូច លទ្ធិភាពនៃឥទ្ធិពលជាអន្តរជាតិដែលអាចធានាបានថា គ្រប់ប្រជាជាតិទាំងអស់ សុទ្ធតែទទួលបានឱកាសក្នុងការចូលរួមទាមទារចំណែកសមុទ្រ ហើយធនធានទាំងអស់នោះដែលត្រូវបានបែងចែកយ៉ាងស្មើគ្នា ក៏រួញតូចផងដែរ។

ច្បាប់ទាំងអស់នោះ គឺគ្រាន់តែទាក់ទងជាមួយបាតសមុទ្រតែប៉ុណ្ណោះ។ ប៉ុន្តែទំហំផ្ទៃទឹកខាងលើ នឹងអ្វីៗដែលកើតឡើងខាងលើ និងក្រោមទឹក ក៏ជាប់ទាក់ទងនឹងបទបញ្ញាតាមច្បាប់ផងដែរ។ នៅក្នុងតំបន់សេដ្ឋកិច្ច ច្បាប់ជាតិ ត្រូវបានអនុវត្ត លើការទាញយកផលប្រយោជន៍លើធនធានសមុទ្រ និងការការពារបរិស្ថាន។ បន្ថែមពីលើនេះទៅទៀត ច្បាប់លើសមុទ្រអន្តរជាតិដែលត្រូវបានប្រើប្រាស់ ក៏ជាផ្នែកមួយនៃច្បាប់អន្តរជាតិ។ កង្វះខាតគឺ នៅតែមាន ពោលគឺថា អ្នកណាដែលអាច ចាប់ចោរសមុទ្របាន អាចរឹបអូសវាទុក តែមិនសំដៅទៅលើ អ្នកបំពុលបរិស្ថាន អ្នកចាប់ត្រីខុសច្បាប់ ភេរវជន ឈ្មួញជួញដូរអាវុធ អ្នករត់ពន្ធគ្រឿងញៀន ឬអ្នកជួញដូរមនុស្ស នោះទេ។ ពួកគេទាំងនោះត្រូវបានចាប់ និង ដាក់ទោសតាមប្រទេសដើមរបស់ពួកគេមក តែប៉ុណ្ណោះ។ ជាញឹកញាប់ ពុំមានគោលការច្បាស់លាស់ថានរណា គឺជាអង្គភាពទទួលបន្ទុកលើការងារទាំងអស់នេះ។ បើនិយាយតាមគោលការអធិបតេយ្យភាពសមុទ្រអន្តរជាតិ មិនមែនជារបស់នរណាម្នាក់ទេ ក៏ដូចគ្នាដែរ នៅពេលដែលយើងគិតដល់ការទាញយកផលប្រយោជន៍លើវា វាជារបស់មនុស្សគ្រប់គ្នា។ វាពិតជាពិបាកក្នុងការរឹតបន្តឹងការការពារ លើមហាសមុទ្រជាមួយ នឹងបញ្ហាសកល។ ប៉ុន្តែ វាអាចទៅរួច តាមរយៈការចរចារនាពេលបច្ចុប្បន្ន ដើម្បីបង្កើតតំបន់អភិរក្សក្នុងសមុទ្រអន្តរជាតិ តាមកម្រិតរបស់អង្គការសហប្រជាជាតិដែលអាចបង្ហាញចេញជាលទ្ធផល •


Large sea grass
Blue mussel


Cobalt (Co)
20.5
94
Manganese (Mn)
5,830
7,076
31
260
Rare earth oxides
Thallium


Number of invasive species
0
1–2
3–7
8–15
16–30
31–56
Introduction without effects
on native species
Main trade routes
(> 500 ship journeys per year)